**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចល្អខណ្ឌច្បារអំពៅរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ក. ជា គន្ធា**

**ក. ឱន ស្រីនាថ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉ែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១២

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ សូមក្រាបប្រណិប័តន៍ ថ្លែងអំណរគុណដោយក្តីកតញ្ញូតាធម៌ និងដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ដល់លោកអ្នកដែលមានគុណ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅដល់រូបកូន។

ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះលោកយាយ លោកតា លោកអ៊ុំប្រុស លោកអ៊ុំស្រី ពូមីង និង បងប្អូនប្រុស ស្រីរបស់យើងខ្ញុំទាំងអស់ដែលបានផ្តល់ជាកម្លាំងចិត្តឲ្យនាងខ្ញុំរហូតមក។

សូមអនុញ្ញាតថ្លែងអំណរគុណជូន

អ្នកមានគុណទី២របស់យើងខ្ញុំ គឺសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញ ណែនាំ ផ្តល់នូវចំណេះដឹង ចំណេះធ្វើ ចង្អុលបង្ហាញនូវមាគ៌ាត្រចះត្រចង់មានតម្លៃ និងមានប្រយោជន៍សម្រាប់អនាគតដ៏រុងរឿងដល់យើងខ្ញុំ។

លោកសាស្ត្រាចារ្យ បណ្ឌិត **ឈុន ណារ៉េត** និងលោកអភិបាល **ចេង មុនីរ៉ា** នៃខណ្ឌច្បារអំពៅ ព្រមទាំងសមាសជិកខណ្ឌច្បារអំពៅទាំងអស់ ដែលបានចូលរួមសកម្មភាពជួយជ្រោមជ្រែងស្មារតី គំនិត និងយកចិត្តទុកដាក់ក្នុងដំណើរការស្រាវជ្រាវ ក្នុងការសរសេររបាយការណ៍ស្រាវជ្រាវ ក្រោមប្រធានបទស្តីពី "**អភិបាលកិច្ចល្អខណ្ឌច្បារអំពៅបច្ចុប្បន្ន**" នេះអោយសម្រេចបានជោគជ័យ ។

ជាចុងក្រោយនៃកថានេះ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីសួស្តី ជ័យមង្គល កើតមានដល់អស់លោកអ្នកមានគុណទាំងឡាយ និង សូមអោយលោកជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ខណ្ឌ គឺជាកម្លាំងរដ្ឋបាលសាធារណៈរបស់ជាតិយ៉ាងសំខាន់នៅក្នុងការអនុវត្តកម្មវិធីគោលនយោបាយជាតិ។ ប្រសិនជាក្នុងប្រទេសមួយមិនមានការពង្រឹងគោលនយោបាលរបស់ខ្លួននៅក្នុងថ្នាក់ខណ្ឌទេនោះ ប្រទេសនោះច្បាស់ជាលំបាកក្នុងការធ្វើឲ្យមានប្រសិទ្ធភាព លើទិសដៅការងាររបស់ខ្លួនជាក់ជាមិនខាន។ លើសពីនេះទៅទៀត សមាជិកនៅក្នុងខណ្ឌ ក៏ដូចជាប្រជាពលរដ្ឋនៅក្នុងប្រទេសផងដែរ ដូចនេះការស្មារតី និង គុណភាពការងារ នៅថ្នាក់ខណ្ឌរបស់ជាតិសំខាន់ជាងនេះទៅទៀត គឺបានធ្វើឲ្យប្រជាពលរដ្ឋមានស្មារតីទទួលខុសត្រូវខ្ពស់របស់សង្គមរបស់ខ្លួន និងជាចំណុចសំខាន់មួយក្នុងការធ្វើឲ្យមានការរីកចម្រើននៅក្នុងសង្គម ក៏ដូចជារបស់ប្រជាជាតិនោះ។

វត្ថុបំណងនៃការជ្រើសរើសយកប្រធានបទ អភិបាលកិច្ចល្អខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មកសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ គឺចង់បង្ហាញពីផ្នែកមួយនៃសកម្មភាពផែនការអភិវឌ្ឍន៍ខណ្ឌ ភូមិសាស្ត្រ ប្រជាសាស្ត្រ សកម្មភាពការងារ លទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅសកម្មភាពការងារប្រចាំឆ្នាំ២០១៩ ក្នុងខណ្ឌច្បារអំពៅមកបង្ហាញ និងធ្វើឲ្យមានការយល់ដឹងផងដែរចំពោះសកម្មភាពការងារបច្ចុប្បន្ន និងទិសដៅការងារនាពេលអនាគតរបស់ខណ្ឌច្បារអំពៅក្នុងការបម្រើប្រជាពលរដ្ឋ។

ថ្វីត្បិតតែសារណាស្រាវជ្រាវឯកសារបញ្ចប់ការសិក្សានេះ បានលើកបង្ហាញពីសកម្មភាពការងាររបស់សមាជិកក្រុមប្រឹក្សាក្នុងខណ្ឌទាំងឥក៏ដោយ ប៉ុន្តែក៏នៅតែមិនអាចឆ្លើយតបទៅនិងតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់ជ្រុងជ្រោយនៃទិសដៅការងារ និងទិសដៅសកម្មភាពរបស់ខណ្ឌទាំងមូលផងដែរ។

ដូច្នេះសារណា ក្នុងការស្រាវជ្រាវឯកសារបញ្ចប់ការសិក្សានេះ សូមអធ្យាស្រ័យផងដែរចំពោះរាល់ចំណុចខ្វះខាតទាំងឡាយណាដែលបានកើតមានឡើងចំពោះខ្លឹមសារ និងការបកស្រាយនៅក្នុងសារណានេះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**......01

**ជំពូកទី១**

**ស្ថានភាពទូទៅនៅខណ្ឌច្បារអំពៅ**

**១.១. ស្ថានភាពភូមិសាស្រ្ត និងស្ថានភាពប្រជារាស្រ្ត**......05

១.១.១.ស្ថានភាពភូមិសាស្រ្ត......05

១.១.២.ស្ថានភាពប្រជារាស្រ្ត......06

១.១.៣.ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច......06

**១.២. ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ**......07

១.២.១.និយមន័យអភិបាលកិច្ចល្អ......07

១.២.២.គោលការណ៍នៃអភិបាលកិច្ចល្អ......07

**ជំពូកទី២**

**សកម្មភាពការងាររបស់ខណ្ឌច្បារអំពៅ**

**២.១. តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ខណ្ឌ**......12

២.១.១.រចនាសម្ព័ន្ធរបស់ខណ្ឌ......12

២.១.២.តួនាទីភារកិច្ច......13

២.១.២.១.សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខណ្ឌ......13

២.១.២.២.តួនាទីរបស់គណៈអភិបាលខណ្ឌ......14

២.១.២.៣.តួនាទីរបស់អភិបាលខណ្ឌ......16

២.១.២.៤. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ......18

២.១.២.៥.នាយករដ្ឋបាល......19

២.១.២.៦.គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា......20

២.១.២.៧.ការិយាល័យចំណុះរដ្ឋបាលសាលាខណ្ឌច្បារអំពៅ......22

**២.២. ភូមិឃុំមានសុវត្ថិភាព**......23

**២.៣. ប្រជាការពារ**......24

**២.៤. ការបង្កើតផែនការអភិវឌ្ឍន៍ខណ្ឌ**......24

**២.៥. សកម្មភាពប្រចាំឆ្នាំ២០១៨**......26

២.៥.១.គិតពីសេវាសាធារណៈ......26

២.៥.១.១.ការងារអត្រានុកូលដ្ឋាន.....27
២.៥.១.២.ការងារច្រកចេញចូលតែមួយ.....27
២.៥.១.៣.សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ.....28
២.៥.១.៤.ប័ណ្ណមូលនិធិសមធម៌.....29
២.៥.១.៥.សេវាសុខាភិបាល.....29
២.៥.១.៦.ការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន.....31
២.៥.២.ការចូលរួមរបស់ប្រជាពលរដ្ឋ.....32
២.៥.២.១.ការចុះឈ្មោះនិងពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត.....32
២.៥.២.២.ការងាររៀបចំវេទិកាសាធារណៈ.....33
២.៥.២.៣.ការចូលរួមរបស់ប្រជាពលរដ្ឋជានារីក្នុងមូលដ្ឋាន.....33
២.៥.២.៤.ការងាររៀបចំដែនដីនគរូបនីយកម្មនិងសំណង់.....36
២.៥.៣.ការពង្រឹងនីតិរដ្ឋ.....36
២.៥.៤.ការជម្រុញឲ្យមានតម្លាភាពនិងការឆ្លើយតប.....36
២.៥.៥.ការទទួលខុសត្រូវនិងគណនេយ្យភាព.....38

## ជំពូកទី៣

## លទ្ធផលនៃការអនុវត្តការងារ និងទិសដៅសកម្មភាពនាពេលអនាគត

**៣.១. ការគិតគូរពីសេវាសាធារណៈ**.....39
៣.១.១.សេវាអត្រានុកូលដ្ឋាន.....39
៣.១.២.សេវាសុខាភិបាលក្នុងមូលដ្ឋាន.....41
៣.១.៣.សេវាអប់រំ.....42
**៣.២. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន**.....43
**៣.៣. ការទទួលខុសត្រូវ និងគណនេយ្យភាពរបស់ខណ្ឌ**.....44
**៣.៤. សមត្ថភាពមន្ត្រីក្នុងការជម្រុញអភិបាលកិច្ចល្អ**.....45
**៣.៥. បញ្ហាប្រឈម**.....46
**៣.៦.ទិសដៅសកម្មភាពនាពេលអនាគត**.....48
**សេចក្តីសន្និដ្ឋាន**
**អនុសាសន៍**
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ខណ្ឌច្បារអំពៅ ជាខណ្ឌទី៧ដែលស្ថិតក្នុងចំណោមខណ្ឌទាំង១២ នៃរាជធានីភ្នំពេញ មានព្រំប្រទល់ខាងជើងទល់នឹង ទន្លេមេគង្គ ស្រុកល្វាឯម ខេត្តកណ្តាល ខាងត្បូងទល់នឹង ទន្លេបាសាក់ ក្រុងតាខ្មៅ និងស្រុកស្អាង ខេត្តកណ្តាល ខាងលិចទល់នឹងទន្លេបាសាក់ ខណ្ឌមានជ័យ និងក្រុងតាខ្មៅ ខេត្តកណ្តាល ខាងកើតទល់នឹង ស្រុកកៀនស្វាយ ខេត្តកណ្តាល។ មានផ្ទៃដីទំហំ ៨០.៩៥គីឡូម៉ែត្រការ៉េ០.៨៥១ម² ចែកចេញជា៨សង្កាត់ និង៥៩ភូមិ មានប្រជាពលរដ្ឋសរុបចំនួន១២៧,៦០៥នាក់ ស្រី៦៥,៥៥១នាក់ មានដង់ស៊ីតេ ប្រជាជន១,៥៧៦នាក់/គ.ម²[1]។

ខណ្ឌច្បារអំពៅជានីតិបុគ្គល និងជាសមូហភាពដែនដីរបស់រដ្ឋក្នុងការបម្រើសេវាកម្មរដ្ឋបាលសាធារណៈជូនប្រជាពលរដ្ឋ ស្របទៅតាមឋានានុក្រម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងធានាសន្តិសុខសណ្តាប់ធ្នាប់ និងភាពសុខដុមរមនារបស់ប្រជាពលរដ្ឋក្នុងសង្គម។ សម្រាប់ប្រទេសកម្ពុជា ខណ្ឌ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩០៣ -១៩០៤ ដោយអាណានិគមនិយមបារាំង ហើយត្រូវបានបញ្ជាក់ជា បន្តបន្ទាប់ ដោយព្រះរាជប្រកាស ០៥\០៦\១៩០៨, ២៥\០៩\១៩១៩ ហើយជាពិសេសនោះគឺ ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់ជំពូកទី១៣ មាត្រា១៤៥[2]។ ខណ្ឌច្បារអំពៅ បានបង្កើតឡើងយោងតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ៥៧៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣។ ខណ្ឌច្បារអំពៅត្រូវ បានបំបែកចេញពី ខណ្ឌមានជ័យនៅឆ្នាំ២០១៣។ នៅពេលបច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិ ខណ្ឌ ជាស្ថាប័នមួយដែលធ្វើការគ្រប់គ្រង និង បម្រើផលប្រយោជន៍ជូន ប្រជាពលរដ្ឋដែលស្ថិតក្នុងមូលដ្ឋានភូមិ សង្កាត់ ខណ្ឌរបស់ខ្លួន។

ផ្អែកតាមការវិវឌ្ឍន៍នៃស្ថានភាពប្រែប្រួលនៃប្រទេសកម្ពុជា ដើម្បីពង្រឹង និង ពង្រីកប្រសិទ្ធិភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងមូលដ្ឋានខណ្ឌច្បារអំពៅ បានកំណត់ និង ដាក់ចេញនូវទស្សនវិស័យ ការអនុវត្ត និង បានរំពឹងទុកចំពោះសមិទ្ធផលដែលត្រូវបានទទួលក្នុងឆ្នាំ២០១៨តាមរយៈផែនការអភិវឌ្ឍន៍ គ្រប់ផ្នែកទាំងអស់របស់ខ្លួន។ តាមរយៈផែនការអភិវឌ្ឍន៍ និង ទិសដៅសកម្មភាពនេះ បានរំលេចឲ្យឃើញពីតម្រូវការ នៃការចូលរួមសហការរបស់ប្រជាពលរដ្ឋ ជាមួយខណ្ឌ ក្រុមប្រឹក្សាខណ្ឌ ដែលជាការចូលរួមចំណែកជួយជ្រោមជ្រែងលទ្ធភាពការងាររបស់ខណ្ឌ ឲ្យឈានទៅបានសម្រេចជោគជ័យ។

[1] សៀវភៅ ផែនការអភិវឌ្ឍន៍របស់ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឆ្នាំ២០១៥-២០១៩

[2] ជំពូកទី១៣ មាត្រា១៤៥ នៃច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

ហេតុនេះហើយ ការយល់ដឹងរបស់ប្រជាពលរដ្ឋពី អភិបាលកិច្ចល្អនៅក្នុងមូលដ្ឋានខណ្ឌ ពិតជារឿងចាំបាច់ និង ជាការចូលរួមចំណែកលើកស្ទួយ អភិបាលកិច្ចល្អ ក្នុងវិស័យអភិវឌ្ឍន៍ រៀបចំរបៀបរៀបរយ និង រក្សាការពារសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គមទាំងមូលក្នុងមូលដ្ឋានខណ្ឌ ក៏ដូចជាការផ្តល់សេវា ផ្សេងៗ ដែលជាសមត្ថកិច្ចរបស់ខណ្ឌច្បារអំពៅ ជាពិសេសការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានភូមិ សង្កាត់ ឲ្យទាន់ពេលវេលា និង មានប្រសិទ្ធិភាព។

ស្របតាមស្ថានភាពខាងលើ ប្រទេសកម្ពុជាចាំបាច់ត្រូវមានខណ្ឌ ដែលពោរពេញទៅដោយសមត្ថភាព និង មានការទទួលខុសត្រូវខ្ពស់ ទើបមានការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ និង អាចធានាបាននូវប្រសិទ្ធិភាពការងារ ក្នុងការអនុវត្តសកម្មភាព និង គោលការណ៍របស់ខ្លួន ហើយអាចគ្រប់គ្រងស្ថានភាពចាំបាច់នៅក្នុងខណ្ឌ ក្នុងពេលមានសកម្មភាពរបស់សមាជិកក្រុមប្រឹក្សាខណ្ឌ ពុំមានភាពចុះសម្រុងគ្នាទៅលើបញ្ហាដែលបានលើកឡើង ហើយបញ្ហានោះគឺជាតម្រូវការរបស់ប្រជាពលរដ្ឋបានស្នើសុំនោះអាចបណ្តាលឲ្យមានការមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋដោយសារ ទង្វើមិនគួរគប្បីរបស់សមាជិកក្រុមប្រឹក្សាខណ្ឌ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បញ្ហាដែលកើតមានឡើងនៅពេលបច្ចុប្បន្ននោះ គឺជាបញ្ហាដែលទាក់ទងទៅនឹងស្ថានភាពសកម្មភាព និងបញ្ហារបស់ខណ្ឌ ដែលបានជះឥទ្ធិពលដល់ប្រសិទ្ធិភាពក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ក្នុងគោលនយោបាយជាតិ ជាពិសេសចំពោះវិស័យរដ្ឋបាលសាធារណៈ និង សន្តិសុខរបស់ខណ្ឌ ក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។

ចំណោទបញ្ហាដែលលើកយកមកចោទសួរក្នុងប្រធានបទមាន៖

តើខណ្ឌច្បារអំពៅមានស្ថានភាពយ៉ាងដូចម្តេច?

តើខណ្ឌច្បារអំពៅមានសកម្មភាពយ៉ាងដូចម្តេចខ្លះ?

តើខណ្ឌច្បារអំពៅបានជួបប្រទះនិងបញ្ហាអ្វីខ្លះ នឹងមានទិសដៅយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញដោយគោរពតាមផែនការកម្មវិធីវិនិយោគរបស់ខណ្ឌ បានបង្ហាញពីការដឹកនាំអភិវឌ្ឍន៍ដែលមានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ។ ថ្វីត្បិតតែ របាយការណ៍ការស្រាវជ្រាវឯកសារនេះ បានបង្ហាញអំពីការងារត្រឹមត្រូវកម្រិតខណ្ឌក៏ពិតមែន តែបានឆ្លុះបញ្ចាំងនូវទិសដៅសកម្មភាពនៃខណ្ឌ ចំពោះការចូលរួមយ៉ាងសកម្ម ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងមានការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាខណ្ឌ ទូទាំងរាជធានី ភ្នំពេញផងដែរ។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវឯកសារក្រោមប្រធានបទ អភិបាលកិច្ចល្អ នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញបច្ចុប្បន្ន បានលើកបង្ហាញអំពីសកម្មភាពការងារជាច្រើនដែលគ្រប់ផ្នែកទាំងអស់ គឺស្ថិតក្រោមការដឹកនាំរបស់អភិបាលខណ្ឌ ប្រធានក្រុមប្រឹក្សាខណ្ឌបានអនុវត្ត និង សម្រេចជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌ សង្កាត់ និង ការងារសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការតាមដាន និង វាយតម្លៃដើម្បីឈានទៅរកភាពរីកចម្រើន ទូទាំងខណ្ឌច្បារអំពៅ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ដើម្បីបំផុសការយល់ដឹងជាសាធារណៈ ទៅកាន់ប្រជាពលរដ្ឋទូទៅ និង សិស្សនិស្សិត ឲ្យមានការយល់ដឹងអំពីផ្នែកមួយនៃគោលនយោបាយជាតិ ចំពោះក្រុមប្រឹក្សាខណ្ឌច្បារអំពៅ ក៏ដូចជាការលើកកំពស់ស្មារតីទទួលខុសត្រូវខ្ពស់របស់ខណ្ឌច្បារអំពៅ ផងដែរ។ ហើយយើងខ្ញុំមានជំនឿថា របាយការណ៍ស្រាវជ្រាវឯកសារនេះ គឺប្រៀបដូចជាអ្នកនាំពាក្យ របស់ខណ្ឌក្នុងការចេញមុខការពារតម្លៃសកម្មភាពរួមទាំងអស់គ្នា បម្រើប្រជាពលរដ្ឋ និង មានទស្សនៈវិស័យរួមគ្នាដើម្បីភាពរីកចម្រើនរបស់ខណ្ឌជាតិកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ត្រូវបានបង្កើតឡើងដោយប្រមូលផ្តុំនូវឯកសារមួយចំនួនដែលទាក់ទងទៅនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផ្អែកលើទិន្នន័យនៃរបាយការណ៍បូកសរុបសមិទ្ធផលប្រចាំឆ្នាំ នៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាខណ្ឌ ព្រមទាំងច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទៀត។ហើយក៏មានការស្រាវជ្រាវបន្ថែមដោយប្រមូលយកព័ត៌មានមួយចំនួនដែលបានមកពីការសិក្សារៀនសូត្រលើមេរៀនកន្លងមក និងការចុះទៅសិក្សាផ្ទាល់នៅខណ្ឌច្បារអំពៅផងដែរ។

## ៧. រចនាសម្ព័ន្ធនៃស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយទៅលើការស្រាវជ្រាវមួយនេះ ជាដំបូងខ្ញុំសុំបង្ហាញពីការបែងចែកប្លង់នៃការសិក្សាស្រាវជ្រាវនេះជាមុនសិន ជាក់ស្តែងសារណាមួយនេះត្រូវបានបែងចែកជា ៣ជំពូករួមមាន៖

**ជំពូកទី១៖** បង្ហាញពី ស្ថានភាពទូទៅនៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដោយបានលើកឡើងពី ស្ថានភាពភូមិសាស្ត្រ ស្ថានភាពប្រជាសាស្ត្រ និង ទិដ្ឋភាពទូទៅជុំវិញក្របខណ្ឌនៃអភិបាលកិច្ចល្អ។

**ជំពូកទី២៖** បង្ហាញពី សកម្មភាពការងាររបស់ខណ្ឌច្បារអំពៅ ដោយបានលើកឡើងពី តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និង ការបង្កើតផែនការអភិវឌ្ឍន៍ខណ្ឌច្បារអំពៅ។

**ជំពូកទី៣៖** លទ្ធការងារ បញ្ហាប្រឈម និងទិសដៅសកម្មភាពនាពេលអនាគត ដោយបានលើកឡើងពីលទ្ធផលការងារតាមផ្នែកនីមួយៗ បញ្ហាប្រឈមដែលខណ្ឌមិនទាន់បានដោះស្រាយ និង ទិសដៅសកម្មភាពបន្តសម្រាប់ឆ្នាំបន្ទាប់ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងខណ្ឌច្បារអំពៅ។

# ជំពូកទី១៖ ស្ថានភាពទូទៅនៅខណ្ឌច្បារអំពៅ

## ១.១. ស្ថានភាពភូមិសាស្ត្រ និងស្ថានភាពប្រជារាស្ត្រ

ភូមិសាស្ត្រ និង ប្រជាសាស្ត្រ គឺជាកត្តាដ៏សំខាន់ក្នុងការបង្កើតផែនការ ឬ ទិសដៅសកម្មភាពផ្សេងៗរបស់ខណ្ឌ ដែលមានសមត្ថកិច្ចពាក់ព័ន្ធ។ ព្រោះថាការស្វែងយល់ពីកត្តាទាំងនេះអាចឲ្យថ្នាក់ដឹកនាំ ឬ អ្នកទទួលភារកិច្ចនោះបានដឹង និង ស្វែងយល់បានពីតម្រូវការជាក់ស្តែង និង បញ្ហាដែលកើតមានឡើងក្នុងភូមិសាស្ត្រនោះអាចត្រៀម ឬ លើកផែនការដើម្បីឆ្លើយតបជាមួយសភាពការណ៍ទាំងនោះក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធិភាព។

ដូច្នេះការស្វែងយល់ឲ្យបានស៊ីជម្រៅអំពីផ្នែកភូមិសាស្ត្រ និង ប្រជាសាស្ត្រនៃតំបន់មួយគឺពិតជាមានសារៈសំខាន់ និង មិនអាចមើលរំលងបានឡើយ។ យ៉ាងណាមិញ ប្រជាជនទាំងនោះគឺ មានបញ្ហាផ្សេងៗគ្នា តម្រូវការចាំបាច់ផ្សេងគ្នា ចំណេះដឹងខុសៗគ្នា ការប្រកបរបរចិញ្ចឹមជីវិតខុសគ្នាកម្រិតជីវភាព និងការទទួលផលប្រយោជន៍ពីការរីកចម្រើនរបស់ខណ្ឌខុសៗគ្នាទាំងអស់។ កត្តាទាំងនេះគឺបានជះឥទ្ធិពល និងពាក់ព័ន្ធដល់ការងារអភិវឌ្ឍន៍របស់ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ[3]។

### ១.១.១. ស្ថានភាពភូមិសាស្ត្រ

ខណ្ឌច្បារអំពៅ ជាខណ្ឌមួយទើបតែបង្កើតថ្មីដែលបានបំបែកចេញពីខណ្ឌមានជ័យ។ នៅក្នុងរបប សាធារណៈរដ្ឋខ្មែរ ឃុំច្បារអំពៅត្រូវបានប្តូរជាខណ្ឌច្បារអំពៅក្រុងភ្នំពេញ។ ដូច្នេះទើប រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញដោយកាត់យក សង្កាត់ចំនួន០៨ពីខណ្ឌមានជ័យនៃ រាជធានីភ្នំពេញ គឺ សង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់ព្រែកប្រា សង្កាត់និរោធ សង្កាត់ព្រែកថ្មី សង្កាត់ក្បាលកោះ សង្កាត់ព្រែកឯង សង្កាត់វាលស្បូវ[4]។ ខណ្ឌច្បារអំពៅត្រូវបានសម្ពោធឡើងជាផ្លូវការនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤។ ខណ្ឌច្បារអំពៅស្ថិតនៅភូមិគ្រឹះលេខ ៣ ផ្លូវលេខ៣៦១ ភូមិព្រែក សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ។

សព្វថ្ងៃខណ្ឌច្បារអំពៅមានផ្ទៃដីសរុប ៨០.៩៥ហិចតា ០.៨៥១ម$^{២}$ ក្នុងនោះរួមមានៈ ផ្ទៃដីកសិកម្ម ៣៩៩ហិចតា ផ្ទៃដីលំនៅដ្ឋាន ៧.៦៦៧ហិចតា៨៥៥១ម$^{២}$។

មានព្រំប្រទល់ខាងជើងទល់នឹង ទន្លេមេគង្គ ស្រុកល្វាឯម ខេត្តកណ្តាល ខាងត្បូងទល់នឹង ទន្លេបាសាក់ ក្រុងតាខ្មៅ និងស្រុកស្អាង ខេត្តកណ្តាល ខាងលិចទល់នឹងទន្លេបាសាក់ ខណ្ឌមានជ័យ និង ក្រុងតាខ្មៅ ខេត្តកណ្តាល ខាងកើតទល់នឹង ស្រុកកៀនស្វាយ ខេត្តកណ្តាល[5]។

[3] ជា ផារី ″អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យ ខេត្តកំពតបច្ចុប្បន្ន ″ឆ្នាំ២០១៦ ទំព័រ ទី៩

[4] អនុក្រឹតលេខ ៥៧៩ អនក្រ. បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៣

[5] របាយការណ៍ការស្រាវជ្រាវបង្កើតខណ្ឌថ្មី របស់សាលាខណ្ឌមានជ័យ ខែ វិច្ឆិការ ឆ្នាំ២០១៣

ខណ្ឌច្បារអំពៅមានទន្លេ២ គឺទន្លេបាសាក់ និង ទន្លេមេគង្គក្រោម។ ដែលក្នុងនោះផ្ទៃទឹកមានព្រែកចំនួន ៥១ហិចតា ៧២ម$^{២}$ និងប្រឡាយចំនួន២៤ហិចតា ៥១ម$^{២}$។

### ១.១.២.ស្ថានភាពប្រជារាស្ត្រ

ប្រជាពលរដ្ឋដែលរស់នៅក្នុងខណ្ឌច្បារអំពៅមានចំនួន ២៥,១៣២ គ្រួសារ ស្មើរនឹងប្រជាពលរដ្ឋចំនួន ១២៥,៥៣៣នាក់ ដែលក្នុងនោះមានស្រីចំនួន ៦៥,៨៦១នាក់។ ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងចំនួន ៨៩,០៧១នាក់ ស្រី ៤៦,៧២២នាក់។ ចំនួនប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ៩២,១២៦នាក់។ អត្រាកំណើត ៣.៤៣% ស្មើ ៤,៣០៦នាក់ ស្រី ២,១០០នាក់។ អត្រាមរណភាព ០.៣១% ស្មើ ៣៨៩នាក់ ស្រី ១៦៤នាក់។ ដង់ស៊ីតេប្រជាពលរដ្ឋ ១,៥៥៤នាក់/គម[6]។

### ១.១.៣.ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

មុខរបររបស់ប្រជាពលរដ្ឋក្នុងខណ្ឌច្បារអំពៅមានដូចជា៖ ១០%ជាអ្នករាជការ ៤៧%ជាអ្នកលក់ដូរ ២៧%ជាកម្មកររោងចក្រ និង ១៦% ជាកសិករ។ ចំពោះភោជនីដ្ឋានវិញមានចំនួន១៥ទីតាំង។ រោងចក្រចំនួន១២ទីតាំង។ សិប្បកម្មចំនួន១៩១ទីតាំង។ ផ្សារសរុបចំនួន៣( ផ្សាររដ្ឋ២, ផ្សារឯកជន១)។ ធនាគារស្ថាបនាមីក្រូហិរញ្ញវត្ថុ ចំនួន ១៥( ធនាគារ៩, មីក្រូហិរញ្ញវត្ថុ៦)។ ក្លឹបកម្សាន្តចំនួន៩(ខារ៉ាអូខេ៦,ឌីស្កូតែក៣)។ សណ្ឋាគារ ផ្ទះសំណាក់ ចំនួន១៤ទីតាំង( សណ្ឋាគារ៣, ផ្ទះសំណាក់១១)។ អាផាតម៉ិនចំនួន១ទីតាំង។ ទឹកស្អាតចំនួន១ទីតាំង។ ការប្រមូលសម្រាមក្រុមហ៊ុនស៊ីនទ្រីផ្តល់សេវានៅសង្កាត់និរោធ ច្បារអំពៅទី១ ច្បារអំពៅទី២ និងព្រែកប្រា និងរមណីយដ្ឋាន ចំនួន១ទីតាំង(កែច្នៃ)[7]។

### ក. វិស័យអប់រំ

គ្រឹះស្ថានអប់រំរដ្ឋ: វិទ្យាល័យ០៣, អនុវិទ្យាល័យ០៤, បឋមសិក្សា២០, មត្តេយ្យសិក្សា០៥ និង គ្រឹះស្ថានអប់រំឯកជន១៣[8]។

### ខ. វិស័យសុខាភិបាល

វិស័យសុខាភិបាលមានដូចជា មន្ទីរពេទ្យបង្អែក០១, មណ្ឌលសុខភាព០៤, គ្លីនិកឯកជន២ ទីតាំង ,ឱសថស្ថាន ឱសថស្ថានរង ៣២ទីតាំង និងបន្ទប់ពិគ្រោះព្យាបាល និងមាត់ធ្មេញ៦១ទីតាំង[9]។

### គ. វិស័យធម្មការ និងសាសនា

មានវត្តព្រះពុទ្ធសាសនាហិនយាន២៨វត្ត, វត្តធម្មយុត្តនិកាយ០១វត្ត, វិហារព្រះពុទ្ធសាសនា មហាយាន១៥ទីតាំង, វិហារសាសនាឥស្លាម០១ទីតាំង, វិហារគ្រឹស្តសាសនា១៨ទីតាំង[10]។

[6] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៥

[7] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលសាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[8] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[9] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

**ឃ. អង្គការ សមាគម**

មានចំនួន២៤ទីតាំង ក្នុងនោះ អង្គការចំនួន១៩ទីតាំង, សមាគមចំនួន ០៥ទីតាំង[11]។

## ១.២. ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ត្រូវបានកំណត់យ៉ាងទូលំទូលាយ នៅក្នុងក្របខណ្ឌផ្សេងៗគ្នាជាច្រើន ក្នុងនោះក៏មាននៅក្នុងក្របខណ្ឌនយោបាយ និង ក្របខណ្ឌច្បាប់។ អភិបាលកិច្ចល្អនៅក្នុងក្របខណ្ឌច្បាប់ បានលើកបង្ហាញអំពីការគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាដែល ប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននៅខណ្ឌរបស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ[12]។

### ១.២.១. និយមន័យអភិបាលកិច្ចល្អ

ការស្វែងយល់អំពីអភិបាលកិច្ចល្អ ទោះក្នុងក្របខណ្ឌណាក៏ដោយគឺផ្អែកសំខាន់លើវិធីសាស្ត្រក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានទាំងឡាយរបស់អង្គភាព ឬស្ថាប័ន ដើម្បីបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋឲ្យចំទិសដៅ និងទទួលបានប្រសិទ្ធិភាពខ្ពស់[13]។ ក្នុងកម្មវិធីអភិវឌ្ឍន៍អភិបាលកិច្ចរបស់អង្គការសហប្រជាជាតិ ត្រូវបានដាក់ចេញនៅក្នុងរបៀបវារៈ អភិវឌ្ឍន៍ថ្មីប្រកបដោយនិរន្តភាពដែលមានគោលបំណងដើម្បីបញ្ចប់ភាពក្រីក្រ លើកកំពស់ភាពរុងរឿង និង សុខមាលភាពរបស់ប្រជាជន[14]។

### ១.២.២.គោលការណ៍ នៃអភិបាលកិច្ចល្អ

ដើម្បីឲ្យទ្រឹស្តី អភិបាលកិច្ចល្អទទួលបានលទ្ធផល គឺត្រូវរំលេចចេញជាគោលការណ៍ដែលត្រូវអនុវត្តតាម។ ហើយតាមរយៈគោលការណ៍នេះ គឺអាចធ្វើការវាយតម្លៃលើការងារសម្រេចបាន ឬ កម្រិតនៃការទទួលខុសត្រូវ ក៏ដូចជាកម្រិតនៃភាពរីកចម្រើន របស់សង្គមទៅដល់ប្រជាពលរដ្ឋបានទៀតផង។ គោលការណ៍នៃអភិបាលកិច្ចល្អ ជាទូទៅគឺបានរំលេចឡើងនូវលក្ខណៈ៩ចំណុចដូចខាងក្រោម[15]៖

**ទី១៖ ការចូលរួមពីភាគីពាក់ព័ន្ធ** មានន័យថា ការចូលរួមរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចនោះតាមរយៈអ្នកតំណាងក្តី ឬដោយផ្ទាល់ក្តី គឺពិតជាសំខាន់បំផុតក្នុងការធានាថា ព័ត៌មានទាំងឡាយស្តីពីបញ្ហា និង តម្រូវការផ្សេងៗ

[10] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[11] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ២០១៦ ទំព័រទី៣៦

[12] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ចំណុច"អភិបាលកិច្ចល្អ ក្របខណ្ឌច្បាប់" ទំព័រទី២៣

[13] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ

[14] http//www.undp.org

[15] ជា ធារី "អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យ ខេត្តកំពតបច្ចុប្បន្ន" ឆ្នាំ២០១៦ ទំព័រ ទី៦

ត្រូវបានប្រមូលយកមកធ្វើការវិភាគបានល្អិតល្អន់អំពីព័ត៌មានទាំងនោះ។ អាចធ្វើឲ្យក្រុមងាយរងគ្រោះ ឬ ក្រុមភាគតិច បានបង្ហាញអំពីផលប៉ះពាល់នានា ឬ តម្រូវការជាក់ស្តែងរបស់ពួកគេ ចូលទៅក្នុងការពិភាក្សាមុន និងធ្វើសេចក្តីសម្រេចអំពីអ្វីមួយផងដែរ។

**ការចូលរួមដោយផ្ទាល់** គឺមានន័យថា ប្រជាពលរដ្ឋខ្លួនឯង ត្រូវចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចនោះផ្ទាល់តែម្តង។ ហើយការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋអាចធ្វើឡើងតាមរយៈការបង្កើតសហាគមន៍ សមាគមនានា ការឈរឈ្មោះបោះឆ្នោត ឬ ការបញ្ចេញកម្លាំងពលកម្ម និងធនធានរបស់ ប្រជាពលរដ្ឋផ្ទាល់សម្រាប់ដំណើរការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួន។

**ការចូលរួមតាមរយៈអ្នកតំណាង** គឺមានន័យថា ប្រជាពលរដ្ឋអាចមានអ្នកតំណាងរបស់ពួកគាត់ដើម្បីចូលរួមក្នុងដំណើរការពិភាក្សាផ្សេងៗដែលពាក់ព័ន្ធជាមួយពួកគាត់ហើយអ្នកតំណាង គឺត្រូវតំណាងឆន្ទៈ និង ផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ អ្នកតំណាង គឺត្រូវបានប្រជាពលរដ្ឋជ្រើសរើសតាមរយៈវិធីផ្សេងៗដូចជា តាមរយៈការបោះឆ្នោតជាសកល ឬ អសកលជាដើម។ ចំណុចនេះគឺភាគច្រើនសំដៅលើសមាជិក រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ទី២៖ នីតិរដ្ឋ** ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា គឺជាសង្គមដែលមានក្របខណ្ឌច្បាប់គ្រប់គ្រាន់ក្នុងការគ្រប់គ្រង និង ការពារផលប្រយោជន៍ទូទៅ ហើយមនុស្សគ្រប់រូបនៅក្នុងសង្គម គឺស្ថិតក្រោមច្បាប់ទាំងអស់គ្នា គឺចង់សំដៅដល់ការ ការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬ ក្រុមភាគតិចដែលច្បាប់ត្រូវអនុវត្តដោយមិនលំអៀង។ លើសពីនេះទៅទៀតនោះ គឺការមានប្រព័ន្ធទទួលខុសត្រូវយុត្តិធម៌ និង សង្គមកិច្ចពង្រឹងការអនុវត្តច្បាប់ដែលអាចជឿទុកចិត្តបាន[16]។

**ទី៣៖ តម្លាភាព** ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា រាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះ ត្រូវធ្វើឡើងដោយអនុលោមទៅតាមច្បាប់ បទដ្ឋាននានា និង ត្រូវផ្សព្វផ្សាយជាចំហរតាមរយៈប្រព័ន្ធសមស្របមួយទៅកាន់អ្នកដែលទទួលរងនូវផលប៉ះពាល់ទាំងអស់ មុននិងធ្វើការសម្រេចចិត្ត[17]។

ការផ្សព្វផ្សាយជាចំហរអំពីព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់ និងងាយស្រួលក្នុងការស្វែងយល់ ហើយទាន់ពេលវេលាដោយមិនយឺតយ៉ាវឡើយ។

**<u>ឧទាហរណ៍:</u>** ក្រុមប្រឹក្សាខណ្ឌ ពេលធ្វើការសម្រេចចិត្តអំពីអ្វីមួយត្រូវធ្វើដោយបើកចំហរនិងផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធទៅនឹងការសម្រេចចិត្តនោះ ទៅកាន់ប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌរបស់ខ្លួនឲ្យទាន់ពេលវេលា និង ធានានូវភាពជាក់លាក់អំពីព័ត៌មាននោះ ដើម្បីបញ្ចៀស និង កាត់បន្ថយរាល់ការសង្ស័យ និង ការប្រព្រឹត្តអំពើពុករលួយក្នុងការសម្រេចនោះ។

---

[16] ជា ធារី "អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យ ខេត្តកំពតបច្ចុប្បន្ន" ឆ្នាំ២០១៦ ទំព័រ ទី៧

[17] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃ ចំណុចតម្លាភាពទំព័រទី១៣

**ទី៤៖ ការព្រមព្រៀងឯកភាពគ្នា** ក្នុងន័យ អភិបាលកិច្ចល្អ មានន័យថា រាល់ការធ្វើសេចក្ដីសម្រេចអ្វីមួយគឺធ្វើការពិចារណាលើផលប្រយោជន៍ និង តម្រូវការរបស់អ្នកពាក់ព័ន្ធ ដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និង វិធីសាស្ត្រល្អណាមួយដែលបម្រើផលប្រយោជន៍រួម។

គោលការណ៍ណែនាំសម្រាប់សម្របសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា:[18]

**ក. លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នា**

លក្ខខណ្ឌនៃការព្រមព្រៀងឯកភាពគ្នារួមមានៈ

- ការព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា
- ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់
- ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត
- ការយល់ដឹងអំពីគ្នាទៅវិញទៅមក រវាងក្រុមពាក់ព័ន្ធទាំងអស់

**ខ. ដំណើរការនៃការព្រមព្រៀងឯកភាពគ្នា**

ខាងក្រោមនេះជាការណែនាំខ្លះៗ ដើម្បីធ្វើការសម្រុះសម្រួលឲ្យមានការព្រមព្រៀងឯកភាពគ្នា:

- រៀបចំឲ្យមានការជួបជុំគ្នារវាងក្រុមពាក់ព័ន្ធទាំងអស់
- ស្វែងយល់គ្នាទៅវិញទៅមករវាងក្រុមអ្នកពាក់ព័ន្ធទាំងអស់ និង បង្កើតការយោគយល់គ្នាទៅវិញទៅមក
- ពិភាក្សាជាមួយក្រុមពាក់ព័ន្ធទាំងអស់អំពីផលប្រយោជន៍ និង បង្កើតជម្រើសនានា
- សម្រុះសម្រួល ដើម្បីសម្រេចយកជម្រើសល្អមួយ ដែលបម្រើនូវផលប្រយោជន៍រួម ដោយមានការព្រមព្រៀងឯកភាពគ្នាប្រកបដោយសុខដុមរមនា។

**ទី៥៖ សមធម៌** ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេសក្រុមភាគតិច និង ក្រុមងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលំអ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ លើសពីនេះទៅទៀតអាចឲ្យពួកគេមានអារម្មណ៍ថា ពួកគេគឺជាសមាជិកពិតប្រាកដរបស់សង្គម និង មិនត្រូវបានសង្គមបោះបង់ចោលនោះទេ[19]។

សុខុមាលភាពរបស់មនុស្ស សំដៅជាពិសេសលើភាពសប្បាយរីករាយ សុវត្ថិភាព ភាពសុខស្រួល បញ្ហាសន្តិសុខ សុខភាព។ល។ សុខុមាលភាពរបស់មនុស្សម្នាក់ៗ គឺមិនគ្រាន់តែសំដៅលើផ្នែក

---

[18] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួនមហាផ្ទៃចំណុចការព្រមព្រៀងឯកភាពគ្នា ទំព័រទី ១៤ ដល់ទំព័រទី១៥

[19] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចសមធម៌ទំព័រ១៥

រូបកាយប៉ុណ្ណោះទេ ការគាំពារដល់ស្មារតី អារម្មណ៍ផ្លូវចិត្តរបស់មនុស្សទៀតផង។ ហើយតាមរយៈនេះ ក៏បានផ្តល់ ឱកាសគ្រប់គ្រាន់ក្នុងការបញ្ចេញមតិយោបល់ ទាក់ទងដល់តម្រូវការជាក់ស្តែងរបស់ក្រុមភាគតិច និងជនងាយរងគ្រោះទាំងអស់ដែរ។

**ទី៦៖ ប្រសិទ្ធិភាព** ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា រាល់ដំណើរការនៃការធ្វើសេចក្តីសម្រេច និងការអនុម័តលទ្ធផលទាំងអស់ ត្រូវឆ្លើយតបជាមួយសភាពការណ៍ជាក់ស្តែង និងទទួលបានប្រសិទ្ធិភាពខ្ពស់ ហើយលើសពីនេះទៀត ត្រូវប្រើប្រាស់រាល់សមិទ្ធផលទាំងនោះឲ្យបានត្រឹមត្រូវអាចបម្រើផលប្រយោជន៍រួមជាអតិបរមា ដោយភ្ជាប់ជាមួយការសន្សំសំចៃហើយការប្រើប្រាស់ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ និង ធនធានផ្សេងៗទៀតរបស់ អង្គភាព ស្ថាប័ន ប្រកបដោយនិរន្តភាព។

**ទី៧៖ គណនេយ្យភាព** ក្នុងន័យ អភិបាលកិច្ចល្អ មានន័យថា គឺជាការទទួលខុសត្រូវរបស់អ្នកដែលត្រូវអនុវត្ត តួនាទី និង ភារកិច្ចនៅក្នុងដំណើរការនៃការអនុវត្តសេចក្តីសម្រេចនោះ ដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុ នូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្តនោះ[20]។ ហើយគណនេយ្យភាពនេះគឺត្រូវធ្វើចំពោះថ្នាក់ដឹកនាំរបស់ខ្លួន និងចំពោះមុខសាធារណៈជន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់អំពីការសម្រេចចិត្តនេះ។

**<u>ឧទាហរណ៍៖</u>** ស្មៀនឃុំ ទទួលធ្វើសំបុត្រអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងខ្មែរ មួយច្បាប់ចំនួន ១៥.០០០៛ ពីគ្រួសារមួយ និង ធ្វើសំបុត្រអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនជាតិបរទេសមួយច្បាប់ដូចគ្នាចំនួន ៣០.០០០៛ ពីគ្រួសារមួយ ការបង់ថ្លៃសេវាជាក់លាក់មិនស្មើរគ្នាឡើយចំពោះគ្រួសារទាំងពីរនោះ ហើយស្មៀនឃុំត្រូវបង្ហាញបំភ្លឺនៃនីតិវិធីក្នុងការបង់ថ្លៃសេវានេះ ទៅគ្រួសារទាំងពីរនោះឲ្យបានយល់ច្បាប់ អំពីការខុសគ្នាក្នុងការបង់ថ្លៃសេវានេះ។

**ទី៨៖ ការឆ្លើយតប** ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការព្យាយាម ខិតខំប្រឹងប្រែងរបស់អង្គភាពស្ថាប័នដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និង មិនរើសអើងនៅក្នុងក្របខណ្ឌពេលវេលាមួយ ដ៏សមហេតុផល[21]។

ការឆ្លើយតបអាចជា៖ ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំដំណោះស្រាយដែលស្តែងឡើងជាសកម្មភាពដើម្បីដោះស្រាយបញ្ហា ឬ ការលំបាកនានាការឆ្លើយតបបំភ្លឺអំពីមូលហេតុ ដែលមិនអាចឈានដល់ការធ្វើសកម្មភាពដើម្បី ដោះស្រាយបញ្ហា ឬ ការលំបាកទាំងនោះបានសំណើសុំអន្តរាគមន៍ពី ស្ថាប័ន អង្គភាពមានសមត្ថកិច្ច ដើម្បីជួយដោះស្រាយបញ្ហា ឬ ការលំបាកទាំងនោះព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬ ការលំបាក ទាំងនោះ។

[20] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចគណនេយ្យភាពទំព័រទី១៧

[21] សៀវភៅអភិបាលកិច្ចល្អរបស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌក្រសួងមហាផ្ទៃចំណុចការឆ្លើយតបតំព័រទី១៨

**ទី៩៖ ចក្ខុវិស័យជាយុទ្ធសាស្ត្រ** មានន័យថា សម្រាប់ស្ថាប័នសាធារណៈ ឬ អង្គភាពណាមួយ ជាពិសេស គឺសំដៅដល់អ្នកដឹកនាំផ្ទាល់តែម្តង ត្រូវមានទស្សនៈវិស័យវែងឆ្ងាយ ទូលំទូលាយ ល្អិតល្អន់ក្នុងការគ្រប់គ្រង និង ប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធានាបាននូវភាពយូរអង្វែង។ ជាងនេះទៅទៀត អ្នកដឹកនាំត្រូវតែធ្វើការស្វែងយល់ឲ្យបានច្បាស់ពីគ្រប់ទិដ្ឋភាពនានារួមមាន ផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និង សង្គម ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ។

គួរកត់សម្គាល់ នៅក្នុងក្របខណ្ឌខ្លះ គឺអភិបាលកិច្ចល្អត្រូវបានលើកឡើងតែ ៨ ចំណុចតែប៉ុណ្ណោះ។ ជាសរុបនៅក្នុងជំពូកទី១ នេះគឺគ្រាន់តែធ្វើការលើកបង្ហាញ ពីគ្រប់ទិដ្ឋភាពនានាជុំវិញទ្រឹស្តីអភិបាលកិច្ចល្អ ហើយក៏ជាការ ធ្វើការណែនាំឲ្យបានស្គាល់ ពីខណ្ឌច្បារអំពៅ ដែលជាតួឯកនៅក្នុងប្រធានបទ ស្រាវជ្រាវ ឯកសារនេះ[22]។

[22] សៀវភៅ អភិបាលកិច្ចល្អ បោះពុម្ពលើកទី៤ ខែកុម្ភៈ ឆ្នាំ២០១៣

# ជំពូកទី២៖ សកម្មភាពការងាររបស់ខណ្ឌច្បារអំពៅ

## ២.១. តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ខណ្ឌ

ការស្វែងយល់អំពីអភិបាលកិច្ចល្អរបស់ស្ថាប័ន ឬ អង្គភាពមួយ បានធ្វើឲ្យប្រជាពលរដ្ឋ យល់ដឹង និង បង្ហាញឲ្យឃើញពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើឲ្យមានអភិបាលកិច្ចល្អតាម រយៈការតាមដានការប្រតិបត្តិការការងាររបស់ស្ថាប័ន ឬ អង្គភាពនេះ។ បច្ចុប្បន្ន ក្រុមប្រឹក្សាខណ្ឌមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជម្រុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ[23]។

### ២.១.១. រចនាសម្ព័ន្ធរបស់ខណ្ឌ

អនុលោមតាមប្រកាសលេខ ៣៤៨ ប្រ.ក ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃស្ដីពី តួនាទី ភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធនៃសាលាស្រុក ខណ្ឌ បានចែងថា ស្រុក ខណ្ឌនីមួយៗ ត្រូវដឹកនាំដោយអភិបាលស្រុក ខណ្ឌ ០១រូបអមដោយអភិបាលរងស្រុកខណ្ឌ ០៣រូបជា ជំនួយការ ប៉ុន្តែដោយសាតែរាជធានីភ្នំពេញគឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងមហាផ្ទៃបានបន្ថែមអភិបាល រងខណ្ឌ០១រូបទៀត អោយទៅបំពេញការងារតាមសាលាខណ្ឌទាំង៧ របស់រាជធានីភ្នំពេញ។ ដោយឡែកនៅក្នុងខណ្ឌច្បារអំពៅគឺនូវមានអភិបាលខណ្ឌ០១រូប អមដោយអភិបាលរងចំនួន ១១រូប[24]។

អភិបាលខណ្ឌទទួលខុសត្រូវរួមលើកិច្ចការរដ្ឋបាលដែនដី និងទទួលបន្ទុកផ្ទាល់លើកិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងខណ្ឌរបស់ខ្លួន។ ចំណែកអភិបាលរងខណ្ឌ០១រូប ទទួលបន្ទុកការងាររដ្ឋបាលទូទៅ ០១រូប ទទួលបន្ទុកការងារសង្គមកិច្ច និង០១រូបទៀត ទទួលការងាសេដ្ឋកិច្ច និងទទួលភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។ ម្យ៉ាងទៀតសាលាខណ្ឌត្រូវគ្រប់គ្រងដោយប្រធាន ០១រូប ហៅថាប្រធានមន្ទីរខណ្ឌ អមដោយអនុប្រធាន០១រូបជាជំនួយការ។ ប្រធានមន្ទីរខណ្ឌត្រូវបំពេញការងារក្រោមការដឹកនាំអភិបាលរងខណ្ឌក្នុងការដឹកនាំសម្របសម្រួល ការងារនានាចំណុះសាលាខណ្ឌ។ អនុប្រធានមន្ទីរមានភារកិច្ច ជំនួយការឲ្យប្រធានមន្ទីរខណ្ឌ អនុវត្តការងារតាមការប្រគល់ភារកិច្ចរបស់ប្រធានមន្ទីរខណ្ឌ និងជំនួសប្រធានមន្ទីរខណ្ឌពេលអវត្តមាន។ សាលាខណ្ឌមានការិយាល័យចំណុះ ០៣ គឺការិយាល័យរដ្ឋបាលទូទៅ ការិយាល័យសង្គមកិច្ច និង

[23] មាត្រា២៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[24] ប្រកាសលេខ ៣៤៨ប្រ.ក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០០ របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទីភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុកខណ្ឌ

ការិយាល័យសេដ្ឋកិច្ច។ ការិយាល័យចំណុះសាលាខណ្ឌនីមួយៗ ដឹកនាំដោយប្រធានការិយាល័យ ០១ រូប អមដោយអនុប្រធានការិយាល័យ ០១ រូបជាជំនួយការ[25]។

រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ៖




*<u>ប្រភព</u>៖ ក្រសួងមហាផ្ទៃ សៀវភៅណែនាំ"ការិយាល័យច្រកចេញចូលតែមួយ" ឆ្នាំ២០១១*

### ២.១.២. តួនាទី ភារកិច្ច

នៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលខណ្ឌច្បារអំពៅ ត្រូវបានបង្កើតឲ្យមាននូវក្រុមប្រឹក្សា និងគណៈអភិបាល។ ក្រុមប្រឹក្សាខណ្ឌត្រូវបានបង្កើតឡើងដោយការបោះឆ្នោត។ ពួកគេជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ឲ្យប្រជាពលរដ្ឋទាំងអស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

#### ២.១.២.១. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសតាមការបោះឆ្នោតអសកលតាមនីតិវិធីដែលបានកំណត់ក្នុងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជ

[25]កែវ ច័ន្ទរស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី២២

ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលហៅកាត់ថា **ក្រុមប្រឹក្សា**[26]។ ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់[27]។ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[28]។

ក្រុមប្រឹក្សាខណ្ឌមានសិទ្ធិអំណាចពីរគឺៈ សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញាត្តិ និង សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។

ប្រធានក្រុមប្រឹក្សាខណ្ឌក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលខណ្ឌលើៈ ដីការ ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខណ្ឌបានអនុម័តរួច សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខណ្ឌ កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាខណ្ឌបានអនុម័តសំណើរដកហូតអភិបាលខណ្ឌ ឬអភិបាលរងខណ្ឌចេញពីមុខតំណែងតាមការប្រជុំរបស់ក្រុមប្រឹក្សាខណ្ឌ លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខណ្ឌ ប្រតិទិនកិច្ចប្រជុំកិច្ចសាមញ្ញ របស់ក្រុមប្រឹក្សាខណ្ឌសម្រាប់រយៈពេល១២ខែ សំណើរសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខណ្ឌ កិច្ចការដទៃទៀតតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ គណៈអភិបាលខណ្ឌ ត្រូវជួយក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះលើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនិងសំណើរដកហូតអភិបាលខណ្ឌ ឬអភិបាលរងខណ្ឌចេញពីមុខតំណែង[29]។

### ២.១.២.២. តួនាទីរបស់គណៈអភិបាលខណ្ឌ

គណៈអភិបាល បង្កើតឡើងសម្រាប់ដឹកនាំការងារទូទៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គណៈអភិបាលគឺជាការប្រមូលផ្តុំអភិបាល និងអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គណៈអភិបាលកើតឡើងដោយសារការតែងតាំងពីរាជរដ្ឋាភិបាល ឬក្រសួងមហាផ្ទៃ។ គណៈអភិបាលមិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ[30]។ គណៈអភិបាលជាសេនាធិការជាអ្នកទទួលអនុវត្តរាល់សេចក្តី

[26]មាត្រា៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

[27] មាត្រា១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

[28] អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩

[29] មាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

[30] មាត្រា១៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

សម្រេចនិងផ្តល់យោបល់ឲ្យក្រុមប្រឹក្សាដើម្បីឲ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តតាមមុខងារសិទ្ធិអំណាចនិងភារកិច្ចរបស់ខ្លួន។

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើនាយករដ្ឋមន្ត្រីដោយមានការស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[31]។ អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌត្រូវតែងតាំងដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលរងក្រុង ស្រុក ខណ្ឌ តែងតាំងដោយប្រកាសក្រសួងមហាផ្ទៃ។ ចំនួននៃគណៈអភិបាលត្រូវប្រែប្រួលតាមកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ។ គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានពីបី(០៣)រូប ទៅប្រាំ(០៥)រូប[32]។ ចំនួនជាក់ស្តែងនៃគណៈអភិបាលខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

គណៈអភិបាលខណ្ឌមានតួនាទី និងភារកិច្ចដូចជា៖

គណៈអភិបាលខណ្ឌត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌអំពីកិច្ចការនានា ដែលពាក់ព័ន្ធនិងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីឲ្យ ក្រុមប្រឹក្សាខណ្ឌធ្វើការពិភាក្សា និងការអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ។ ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានធ្វើប្រតិភូកម្មមកឲ្យក្រុមប្រឹក្សាខណ្ឌ និងរបៀបរបបបែបបទ នីតិវិធីនៃការអនុវត្តន៍មុខងារ ភារកិច្ច និងចាត់ចែងធនធានទាំងនោះ។ ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផែនការ អនុវត្តន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានីភ្នំពេញ។ ក្របខណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាពការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់ខណ្ឌការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា ការងារបុគ្គលិក និង ក្របខណ្ឌការរៀបចំ តួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិកការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាខណ្ឌពិនិត្យ និងអនុម័តមិនឲ្យលើសពី ៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង៖ ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខណ្ឌ និងសកម្មភាពលទ្ធផលនៃការអនុវត្តន៍ បញ្ហា

[31] មាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

[32] មាត្រា១៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

ហិរញ្ញវត្ថុ និងថវិកាវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខណ្ឌ និងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ វិធានការចាំបាច់ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីលើកកម្ពស់សមភាពយេនឌ័រកិច្ចការផ្សេងៗទៀត និងក្រុមប្រឹក្សាខណ្ឌយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយាការណ៍ប្រចាំឆ្នាំរបស់ខ្លួន។ របាយការណ៍ ប្រចាំខែ ត្រីមាស និងឆមាស ការបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការ អនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាខណ្ឌក្នុងការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន ដូចជាការរៀបចំក្តារព័ត៌មានការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយ ស្វះស្វែងរកព័ត៌មានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវឲ្យក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ ពេលបានទទួលរបាយការណ៍ ឬព័ត៌មានការរំលោភអំណាច គណៈអភិបាលខណ្ឌត្រូវធ្វើការស៊ើប អង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខណ្ឌ ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារាជធានី[33]។

### ២.១.២.៣. តួនាទីរបស់អភិបាលខណ្ឌ

អភិបាលខណ្ឌមានតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខណ្ឌ។ ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលខណ្ឌត្រូវ[34]៖

ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងខណ្ឌអំពីច្បាប់ និងធានាឲ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឲ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខណ្ឌ។ ធ្វើជាប្រធានគណៈបញ្ជាការឯកភាពខណ្ឌ ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងខណ្ឌដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក្នុងខណ្ឌ។ ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខណ្ឌឲ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនិងការិយាល័យ អង្គភាពនិងទីភ្នាក់ងារនីមួយៗនោះ។ សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខណ្ឌ ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណី កិច្ចការទាំងឡាយណា ដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខណ្ឌត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយ

[33] ហៀង សាង "សមត្ថកិច្ច និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" បោះពុម្ពឆ្នាំ២០១១ ទំព័រទី៣១១

[34]កែវ ច័ន្ទរស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី២៦

ផ្អែកតាមគោលនយោបាយរាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌត្រូវសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព និង ទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខណ្ឌ ក្នុងការធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីឆ្លើយតបទៅនិងតម្រូវការជាអាទិភាពរបស់ខណ្ឌ។ ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់។

ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅខណ្ឌរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលខណ្ឌត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលក្រុង ដើម្បីអភិបាលក្រុងធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅអភិបាលក្រុងក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងខណ្ឌរបស់ខ្លួន ឬករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពី តួនាទី ភារកិច្ចរបស់ខ្លួន។ អភិបាលក្រុងត្រូវណែនាំដល់មន្ទីរ អង្គភាពសាមីប្រចាំនៅក្រុង ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មាធិការ ឬក្រុមការងារ ដែលមានការចូលរួមពីរដ្ឋបាលខណ្ឌដែលពាក់ព័ន្ធឲ្យធ្វើការស៊ើបលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដោះស្រាយតាមនីតិវិធី។ មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលក្រុង ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័ន ដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តកម្មបាន[35]។

ហើយជាការពិតណាស់ដែលអាចនិយាយបានថា សង្កាត់ជាសេនាធិការរបស់ខណ្ឌគឺរដ្ឋបាលខណ្ឌ និងរដ្ឋបាលរាជធានីមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត ក្នុងការទំនាក់ទំនងការងារ រដ្ឋបាលនេះដែលក្នុងទំនាក់ទំនងនេះមានដូចជា៖

ក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំឲ្យមានការពិគ្រោះយោបល់សមស្របជាមួយក្រុមប្រឹក្សាសង្កាត់ ដើម្បីធ្វើការសម្របសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមសង្កាត់នានាក្នុងខណ្ឌដើម្បីលើកកម្ពស់ការឆ្លើយតបនូវតម្រូវការរបស់ប្រជាពលរដ្ឋប្រមូលផ្តុំសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ ដែលបាន

[35] សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក

លើកឡើងដោយក្រុមប្រឹក្សាសង្កាត់ ហើយដែលក្រុមប្រឹក្សាសង្កាត់មិនអាចឆ្លើយតបបាន ពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធខិតខំឆ្លើយតបតាមតម្រូវការទាំងនោះ និងគាំទ្រសមត្ថភាពចាំបាច់ដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីឲ្យក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌមានសមត្ថភាពទទួលបាននូវ មុខងារ និងភារកិច្ចដែលត្រូវធ្វើប្រតិភូកម្មកាន់តែច្រើនថែមទៀតពីក្រុមប្រឹក្សារាជធានី សំដៅឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។

ដើម្បីធានាឲ្យក្រុមប្រឹក្សាខណ្ឌ លើកកម្ពស់ក្នុងការបង្កើត និងការជម្រុញក្នុងការធ្វើឲ្យមាន ចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាសង្កាត់ត្រូវទទួលខុសត្រូវៈ ក្នុងការផ្តល់យោបល់ និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌ ដើម្បីធានាថាក្រុមប្រឹក្សាខណ្ឌនៅតែឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាខណ្ឌ អំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមានធ្វើ សហប្រតិបត្តការឲ្យបានពេញលេញជាមួយក្រុមប្រឹក្សាខណ្ឌ ក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

ក្រុមប្រឹក្សានីមួយៗត្រូវសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសង្កាត់ និងសហគមន៍ប្រជាពលរដ្ឋក្នុងខណ្ឌរបស់ខ្លួនដើម្បីកំណត់ជាអាទិភាពក្នុងការផ្តល់សេវា ការអភិវឌ្ឍន៍ និងសំណើ ឬសំណូមពរនានារបស់ប្រជាពលរដ្ឋក្នុងខណ្ឌរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានីភ្នំពេញ។ ក្រុមប្រឹក្សាត្រូវធ្វើការគាំទ្រ ដល់ក្រុមប្រឹក្សាសង្កាត់ដើម្បីធានាក្រុមប្រឹក្សាសង្កាត់អនុវត្តន៍នូវមុខងារនិង ភារកិច្ចក្នុងក្របខណ្ឌនៃអំណាច ដែលបានធ្វើប្រតិភូកម្មឲ្យលើមូលដ្ឋាននៃការគោរព រដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថាក្រុមប្រឹក្សាសង្កាត់បានអនុវត្ត មុខងារ និងភារកិច្ចនេះក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

### ២.១.២.៤. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ

ទំនាក់ទំនងរវាងក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌមានដូចជាៈ អំណាចបញ្ញាតិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខណ្ឌបានសម្រេច គណៈអភិបាលត្រូវទទួលខុសត្រូវអនុវត្តក្នុងនាមក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។ ដូច្នេះ គណៈអភិបាលខណ្ឌ គឺជាអ្នកអនុវត្តន៍ទាំងសេចក្តីសម្រេចខាងបញ្ញាតិ និងខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាខណ្ឌ។ គណៈអភិបាលខណ្ឌត្រូវមាន គណនេយ្យភាពចំពោះក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន អំពីការអនុវត្តន៍សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ និងគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តន៍តាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង

លិខិតបទដ្ឋាននានា។ គណៈអភិបាលខណ្ឌត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌ[36]។

ក្រៅពីទំនាក់ទំនងនានាដូចដែលបានរៀបរាប់ខាងលើ ទំនាក់ទំនងរវាងក្រុមប្រឹក្សាខណ្ឌក៏បានកំណត់នៅក្នុងតួនាទី ភារកិច្ចនិងរបៀបរបបការងាររបស់ក្រុមប្រឹក្សាខណ្ឌគណៈអភិបាលខណ្ឌផងដែរ។

ក្រុមប្រឹក្សាខណ្ឌមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី មានដូចជា៖ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការនារី និងគណៈកម្មាធិការលទ្ធកម្ម។

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើ ក្រុមប្រឹក្សាខណ្ឌអាចបង្កើត គណៈកម្មាធិការផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតថែមនេះមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទីភារកិច្ចរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើនេះទេ។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាខណ្ឌអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់ គណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌ។ ហើយក្នុងការរៀបចំបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខណ្ឌត្រូវពិនិត្យ និងពិចារណាទៅលើចំណុចមួយចំនួនដូចខាងក្រោម៖ ក្រុមប្រឹក្សាខណ្ឌអាចតែងតាំងសមាជិកក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌ គណៈអភិបាលខណ្ឌ អភិបាលរងខណ្ឌ តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់សម្រាប់សមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង។ ក្រុមប្រឹក្សាខណ្ឌអាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង មានការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខណ្ឌ។

#### ២.១.២.៥. នាយករដ្ឋបាល

នាយករដ្ឋបាលមានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និងអភិបាលរងខណ្ឌក្នុងការចាត់ចែងកិច្ចការរដ្ឋបាលនិងធានានិរន្តភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌ។ ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាខណ្ឌត្រូវធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះ គណៈអភិបាលខណ្ឌ អភិបាលខណ្ឌ និងក្រុមប្រឹក្សារបស់ខ្លួន[37]។

ក្នុងការអនុវត្តតួនាទី នាយករដ្ឋបាលខណ្ឌមានភារកិច្ចដូចជា៖ រៀបចំនិងដាក់ជូនគណៈអភិបាលខណ្ឌ ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌ ហើយត្រូវធានាថា កិច្ចការទាំងនោះ

[36] ហៀង សាង "សមត្ថកិច្ច និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" បោះពុម្ពឆ្នាំ ២០១១ ទំព័រទី៣២០

[37] មាត្រា១០៣ អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ នឹងក្រុមប្រឹក្សាគណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ ចុះថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០០៨។

ត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល និងរៀបចំដាក់ជូនអភិបាលខណ្ឌនូវវិធាន និងគោលការណ៍ក្នុងការ អនុវត្តដីការ និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីជូនគណៈអភិបាលខណ្ឌ និងប្រធានក្រុមប្រឹក្សាខណ្ឌ ក្នុងការត្រៀមរៀបសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាខណ្ឌបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ត្រូវតែដាក់ជូនគណៈអភិបាល ដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុនលើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាខណ្ឌក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ ក្រុមប្រឹក្សាខណ្ឌ ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឲ្យកិច្ចប្រជុំទាំងអស់របស់អភិបាលនៃគណៈអភិបាលខណ្ឌធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាខណ្ឌ អភិបាលខណ្ឌ អភិបាលរងខណ្ឌ ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរអង្គភាពការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ គ្រប់គ្រង និងប្រើប្រាស់ ត្រារដ្ឋបាលខណ្ឌឲ្យបានត្រឹមត្រូវតាមការកំណត់ធានារក្សាទុកឲ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ អភិបាលនៃគណៈអភិបាលខណ្ឌ និងរដ្ឋបាលរបស់ខ្លួនបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាខណ្ឌ ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា[38]។

### ២.១.២.៦. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

យោងតាមមាត្រា ១១៤ ក្រុមប្រឹក្សាមានកាតព្វកិច្ចបង្កើតគណៈកម្មាធិការយ៉ាងតិចចំនួន៣ រួមមាន៖ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងគណៈកម្មាធិការលទ្ធកម្ម។

គណៈកម្មាធិការទាំងអស់នេះមានតួនាទី និងភារកិច្ចដូចតទៅ៖

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានតួនាទី និងភារកិច្ច៖ រៀបចំផែនការអភិវឌ្ឍថវិកាសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយការិយាល័យ អង្គភាពរបស់ក្រសួងស្ថាប័ននានា ធ្វើកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលខណ្ឌ កិច្ចសហប្រតិបត្តិការ និង ការសម្រប

[38] មាត្រា១០៤ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលនៃរាជធានីភ្នំពេញ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩

សម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងខណ្ឌការងារទាក់ទងនិងមុខងារ និងធនធាន។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ មានភារកិច្ចដូចជា[39]៖ ចូលរួមក្នុងការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថភាពរបស់ក្រុមប្រឹក្សា និងដើម្បីធ្វើឲ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនិងសមភាពយេនឌ័រស្ត្រី យុវវ័យ និងកុមារ។ ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនិងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំ រំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាពនិងថវិកាក្រុមប្រឹក្សា។ ចូលរួមក្នុងការរៀបចំតាក់តែងត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាទាក់ទងនិងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។ ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតនៃក្រុមប្រឹក្សា ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា សំណូមពរ ឬសំណើនានាដែលគណៈកម្មាធិការនៃក្រុមប្រឹក្សាប្រភេទផ្សេងនោះ មិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន។ លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សា ឬគណៈអភិបាល អំពីវិធានការសមស្របនានា ដើម្បីជម្រុញឲ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធនិងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនិងកិច្ចការស្ត្រីយុវវ័យ និងកុមារស្វែងរកនិងទទួលបានរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ។ ជម្រុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដល់សហគមន៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ជម្រុញឲ្យមានការប្រមូលព័ត៌របស់សហគមន៍អំពីអ្វីដែលបានកើតមានជាប្រចាំពាក់ព័ន្ធនឹងសមភាពពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារនិងមានវិធានការដើម្បីឆ្លើយតប។ រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ។ គ្រប់កិច្ចការប្រឹងប្រែងដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាព យេនឌ័រ ការបង្កើន

[39] ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០០៩

សមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ។ បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សា។

គណៈកម្មាធិការលទ្ធកម្ម មានតួនាទី និងភារកិច្ចធានាឲ្យសកម្មភាពលទ្ធកម្មប្រព្រឹត្តទៅប្រកបដោយភាពស្មោះត្រង់បើកចំហ តម្លាភាព មិនលំអៀងដោយអនុលោមតាមច្បាប់ បទបញ្ញត្តិពី លទ្ធកម្មសាធារណៈដើម្បីការពារផលប្រយោជន៍របស់រដ្ឋបាលសាមី និងប្រជាពលរដ្ឋរបស់ខ្លួន។

**២.១.២.៧. ការិយាល័យចំណុះរដ្ឋបាលសាលាខណ្ឌច្បារអំពៅ**

សាលាខណ្ឌមានការិយាល័យចាំបាច់ដូចជាៈ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យផែនការ និងអភិវឌ្ឍ និង ការិយាល័យអន្តរវិស័យ[40]។

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយ (០១)រូប និងអនុប្រធានមួយ(០១)រូប ជាជំនួយការ។

**ក. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទី** គ្រប់គ្រង និងថែរក្សាត្រារដ្ឋបាលខណ្ឌកំណត់ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋានការងារបុគ្គលិក ក្របខណ្ឌ បៀវត្សនិងកម្រៃផ្សេងៗរបស់មន្ត្រី រៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងាររបស់មន្ត្រី រៀបចំការងារបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី លើកយោបល់លើការបង្កើត ការកែសម្រួល និងការរំសាយការិយាល័យចំណុះសាលាខណ្ឌការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌ រៀបចំសេចក្តីព្រាងរបៀបវារៈ ខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សានិងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាអភិបាល និងអភិបាលរងខណ្ឌ ព្រមទាំងក្រសួងស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញធានារក្សាទុកឲ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារលិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ។ គណៈអភិបាលខណ្ឌ និងរដ្ឋបាលខណ្ឌរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ រៀបចំនិងបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋនៅក្នុងខណ្ឌរបស់ខ្លួនសហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមសាលាសង្កាត់នានាក្នុងខណ្ឌ[41]។

[40] មាត្រា១១៤ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលនៃរាជធានីភ្នំពេញ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩

[41] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ១០១៤ ទំព័រទី៦៤

**ខ. ការិយាល័យផែនការ និងអភិវឌ្ឍមានតួនាទី** សិក្សា និងរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ដើម្បីបញ្ចូលទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ របស់ រាជធានី អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍនានារបស់ខណ្ឌ សិក្សាវាយតម្លៃ និងលើកយោបល់អំពី សមត្ថភាពរបស់ក្រុមប្រឹក្សាសង្កាត់ និងតម្រូវការគាំទ្រ ដើម្បីដោះស្រាយសំណើ សំណូមពរ និងបញ្ហា ប្រឈមនានារបស់សង្កាត់ គាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ក្នុងការកសាង និង ការអនុវត្តផែនការអភិវឌ្ឍ របស់សង្កាត់ ការសម្របសម្រួល ការគាំទ្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងការផ្តល់សេវាក្នុងចំណោម សង្កាត់នានាក្នុងខណ្ឌ កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាននានាដែលតម្រូវ ដោយក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ[42]។

**គ. ការិយាល័យអន្តរវិស័យមានតួនាទីទៅលើ** ការងាដីធ្លី និងសំណង់ ការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា បរិស្ថាន កាកសំណល់ អនាម័យ សួនច្បារ តាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី អនុវត្តមុខងារ ភារកិច្ចផ្សេងទៀតដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីការងារសណ្តាប់ធ្នាប់ សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្សការរំលោភអំណាច និងការដោះស្រាយវិវាទនៅមូលដ្ឋាន[43]។

## ២.២. ភូមិឃុំមានសុវត្ថិភាព

ដើម្បីឲ្យភូមិឃុំមានសុវត្ថិភាព យើងត្រូវអនុវត្តគោលនយោបាយ៩ចំណុចដូចខាងក្រោមៈ

- គ្មានសកម្មភាព លួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និង អំពើហឹង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើស គ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់

ការអនុវត្តន៍នូវវិធានការគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទាំង៩ចំនុចនេះ ជាហេតុដែលនាំ អោយភូមិ ឃុំមានការអភិវឌ្ឍន៍ប្រកបដោយសន្តិសុខ សណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ។ ការបង្កើន

[42] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦៥

[43] សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦៦

ការយកចិត្តទុកដាក់ ទៅលើសន្តិសុខ នៅក្នុងមូលដ្ឋានភូមិ ឃុំ និងបង្ក្រាប ទប់ស្កាត់ រាល់អំពើដែលនាំអោយមានអសន្តិសុខទាំងឡាយ ជាករណីកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ ធ្វើយ៉ាងណាគោរពនិង អភិវឌ្ឍន៍គោលនយោបាយនេះអោយមានដំណើរការល្អតាមរយៈនគរបាលប៉ុស្តិ៍ រដ្ឋបាលខណ្ឌ សង្កាត់ ប្រកបដោយប្រសិទ្ធិភាព ឆ្លើយតប ទៅនឹងការព្រួយបារម្ភ និងតម្រូវការរបស់ប្រជាពលរដ្ឋ។

ទោះជាមានការខិតខំប្រឹងប្រែងអនុវត្ត តាមគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពបានល្អយ៉ាងនេះក្តី ក៏ការអនុវត្តនេះនៅតែមានចន្លោះ ប្រហោង ខ្វះខាតមិនទាន់គ្រប់ជ្រុងជ្រោយ ដែលជាហេតុនាំអោយមានបទល្មើសនៅតែកើតមានឡើងជារើយៗ។

## ២.៣. ប្រជាការពារ

ភូមិ ឃុំមានសុវត្ថិភាព បានចុះប្រជុំ តាមសង្កាត់ទាំង០៨ក្នុងខណ្ឌ សហការជាមួយកម្លាំងប៉ុស្តិ៍ រដ្ឋបាល និងកម្លាំងមកពី រាជធានី ចុះបង្កើតប្រជាការពារតាមភូមិ ដោយមួយភូមិបង្កើតប្រជាការពារចងក្រងជាពីរក្រុម។

ការបង្កើតអោយមានប្រជាការពារ គឺដើម្បីធានាអោយភូមិ ឃុំមានសុវត្ថិភាព លុបបំបាត់រាល់សកម្មភាព ទាំងឡាយណាដែលនាំអោយប្រជាពលរដ្ឋមានការព្រួយបារម្ភនិងមានភាពចលាចលក្នុងសង្គម។ ហើយបានចាត់វិធានការក្នុងការការពារ និងជួយដល់ប្រជាពលរដ្ឋដោយចាត់កម្លាំងនគរបាលប៉ុស្តិ៍ រដ្ឋបាលខណ្ឌ សង្កាត់ ចុះទៅជួយយាមម៉ូតូក្នុងកម្មវិធីផ្សេងៗរបស់ប្រជាពលរដ្ឋដែលប្រជាពលរដ្ឋបានសុំអនុញ្ញាតពីខណ្ឌ សង្កាត់ ដោយពុំគិតពីកម្រៃតបស្នង និងវិធានការផ្សេងៗទៀតដូចជា ដាក់កម្លាំងយាមល្បាត នៅពេលយប់តាមភូមិ តាមផ្លូវតូច ផ្លូវធំ តាមច្រកល្ហកផ្សេងៗដើម្បី ត្រួតពិនិត្យ និងទប់ស្កាត់សកម្មភាពក្រុមក្មេងទំនើងដើរពេលយប់ អំពើលួច ឆក់ ប្លន់ សកម្មភាពចែកចាយគ្រឿងញៀន ក្មេងប្រើប្រាស់គ្រឿងញៀន និងសកម្មភាពផ្សេងទៀតដែលនាំអោយមានភាពចលាចលដល់សង្គម និងផ្តល់ការអភិវឌ្ឍន៍មូលដ្ឋានក្នុងខណ្ឌច្បារអំពៅរាជធានីភ្នំពេញ[44]។

## ២.៤. ការបង្កើតផែនការអភិវឌ្ឍន៍ខណ្ឌ

ការបង្កើតផែនការអភិវឌ្ឍន៍ របស់ខណ្ឌត្រូវបានបង្កើតឡើងដោយត្រូវគោរព និងស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ ជាពិសេស គឺគោរពតាមបទបញ្ញាផ្ទៃក្នុងរបស់ខណ្ឌ។ ដើម្បីធ្វើឲ្យមានភាពល្អប្រសើរនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ខណ្ឌ ក្រុមប្រឹក្សាខណ្ឌ ត្រូវមានវិធានការដូចតទៅ៖

- រៀបចំបញ្ជីឯកសារពាក់ព័ន្ធ
- រៀបចំទម្រង់តារាងវិភាគស្ថានភាពខណ្ឌ

[44] ជា ធារី "អភិបាលកិច្ចល្អនៅឃុំតានីស្រុកអង្គរជ័យខេត្តកំពតបច្ចុប្បន្ន" ឆ្នាំ២០១៦ ទំព័រទី១៨

- ប្រជុំណែនាំអំពីការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ
- អ្នកពាក់ព័ន្ធបញ្ជូនតារាងវិភាគស្ថានភាពមកក្រុមការងារ
- ក្រុមការងារបូកសរុបតារាងវិភាគតារាងដែលបានទទួលពីអ្នកពាក់ព័ន្ធ
- រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សាខណ្ឌ
- ប្រជុំផ្សព្វផ្សាយអំពីការកសាងផែនការអភិវឌ្ឍន៍ខណ្ឌ[45]។

គណៈអភិបាលខណ្ឌច្បារអំពៅ ត្រូវរៀបចំយន្តការ និងប្រព័ន្ធសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធិភាពនៃការអនុវត្តផែនការ។ គណៈអភិបាលខណ្ឌច្បារអំពៅ ត្រូវរៀបចំរបាយការណ៍ស្តីពី លទ្ធផលនៃការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ និងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាខណ្ឌច្បារអំពៅអំពីវឌ្ឍនភាព នៃការអនុវត្តផែនការនេះទៅតាមកាលកំណត់។ គណៈអភិបាលខណ្ឌច្បារអំពៅ ត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សាខណ្ឌច្បារអំពៅ អំពីរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ[46]។

ដើម្បីឲ្យវិធានការ និងផែនការអភិវឌ្ឍន៍សម្រេចបានជោគជ័យ ត្រូវមានការចូលរួមពីក្រុមប្រឹក្សាសង្កាត់។ ក្នុងការអនុវត្តជាក់ស្តែង នៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍សង្កាត់ ក្រុមប្រឹក្សាសង្កាត់ ត្រូវចាត់វិធានការដូចតទៅ៖

- វាយតម្លៃអំពីកម្រិតអត្ថិភាពនៃការអភិវឌ្ឍន៍ និង សកម្មភាពអភិវឌ្ឍន៍នៅក្នុងសង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការរបស់សង្កាត់ និង កំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះដោយផ្អែកទៅលើធនធានទាំងឡាយដែលសង្កាត់មាន និងធនធានដែលទទួលបាន
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវា និងការអភិវឌ្ឍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់សង្កាត់
- ផ្តល់សេវា និងអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យតាមដាន និងវាយតម្លៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតម្លៃកម្រិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងសង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាសង្កាត់ ត្រូវដឹកនាំការងារឲ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សង្កាត់ របស់ខ្លួន។

ផែនការអភិវឌ្ឍន៍សង្កាត់ ត្រូវបានរៀបចំឡើងជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយ ហើយក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និង

[45] សៀវភៅ ផែនការអភិវឌ្ឍន៍របស់ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ ឆ្នាំ២០១៥-២០១៩
[46] ប្រការ៣ សេចក្តីសម្រេចស្តីពី ការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខណ្ឌច្បារអំពៅ

មធ្យោបាយនានាដើម្បីបង្កលទ្ធភាពឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងសង្កាត់របស់ខ្លួន ក្នុងកិច្ចដំណើរការទាំងមូល[47]។

## ២.៥. សកម្មភាពប្រចាំឆ្នាំ២០១៨

សកម្មភាពប្រចាំឆ្នាំ២០១៨ ជាសកម្មភាពដែលមានលក្ខណៈធំទូលាយ និងមានប្រតិទិនការងារច្បាស់លាស់។ ហើយសកម្មភាពការងារប្រចាំឆ្នាំ២០១៨ គឺត្រូវគោរព និងស្របជាមួយផែនការសកម្មភាពរបស់ខណ្ឌ ដែលរួមមានដូចជា៖

### ២.៥.១.គិតពីសេវាសាធារណៈ

សេវាសាធារណៈ គឺជាសេវាចម្បងនៅក្នុងចំនោមសេវាផ្សេងៗដែលមានក្នុងខណ្ឌច្បារអំពៅ។ ក្នុងនោះដែរក្នុងខណ្ឌច្បារអំពៅបានបង្កើតឡើងទើបតែបានមួយអាណត្តិតែប៉ុណ្ណោះ ប៉ុន្តែខណ្ឌនេះបានគិតគូរពី វិស័យសាធារណៈនេះ ជាវិស័យអាទិភាពក្នុងការបម្រើជូនប្រជាពលរដ្ឋ តាមរយៈការធ្វើឲ្យសេវាសាធារណៈកាន់តែមានភាពងាយស្រួល និងសាមញ្ញតាមរយៈការបង្វិតរដ្ឋបាលសាធារណៈបច្ចុប្បន្នឲ្យកាន់តែខិតជិតទៅរកប្រជាពលរដ្ឋ។ តាមរយៈការដាក់ឲ្យអនុវត្តតាម៖

- អនុក្រឹត្យលេខ ៦២ អនក្រ/បក/ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់ថ្លៃជាវសំបុត្រអត្រានុកូលដ្ឋាន និងថ្លៃតែម
- ការបង្កើតឲ្យមាននូវការិយាល័យច្រកចេញចូលតែមួយតាមរយៈប្រកាសអន្តរក្រសួងលេខ៣៨៥ ប្រ.ក. ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យស្តីពី ការកែសម្រួលចំណុច ក និង ខ មាត្រា៥៩ថ្មីស្ទួននៃអនុក្រឹត្យលេខ១៧អនក្រ/បក ចុះថ្ងៃទី១៨ខែមិថុនាឆ្នាំ២០០៨ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអនុត្រានុកូលដ្ឋាន ឆ្នាំ២០០៥

នេះគឺជាទិសដៅដាក់ឲ្យអនុវត្តន៍ស្តីពីអត្រានុកូលដ្ឋាន ដើម្បីបង្ករភាពងាយស្រួល និងរហ័សជាងមុននៃអត្រានុកូលដ្ឋាន[48]។

[47] មាត្រា៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[48] កែវ ច័ន្ទរស្មី“ អភិបាលកិច្ចល្អខណ្ឌមានជ័យ” ឆ្នាំ២០១៤ ទំព័រទី៣១

**២.៥.១.១. ការងារអត្រានុកូលដ្ឋាន**

ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានៈ

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ១៧៥ | ១៥៤ | ៣៨៤ | ៣៥១ | ៤៦២ | ១៥១៦ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១,៣២០ | ១,៣១៤ | ៣,៥០១ | ៣,៤៣៩ | ៣,៩១៦ | ១៣,៤៩០ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ២៩ | ២៨ | ៧៦ | ៨៤ | ១២៤ | ៣៤១ |
| ៤ | សេចក្តីចម្លងសំបុត្រមរណៈភាព | ១៣ | ១៦ | ២៥ | ២៩ | ២១ | ១០៤ |

*ប្រភព៖ របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

**២.៥.១.២. ការងារច្រកចេញចូលតែមួយ**

ដោយអនុវត្តន៍ទៅតាមសេចក្តីសម្រេច របស់រាជរដ្ឋាភិបាលក្រសួងមហាផ្ទៃបានដាក់ចេញនូវប្រកាសស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយទៅតាមបណ្តា ក្រុង ស្រុក ខណ្ឌ។ ក្នុងការបង្កើតឡើងនូវការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ មានគោលបំណងសំខាន់ៗដូចខាងក្រោមៈ លើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឲ្យបានទូលំទូលាយតាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ ក្រុងស្រុក ខណ្ឌដែលបានផ្តល់ជូនអតិថិជននៅក្នុងកន្លែងតែមួយ។ កែលម្អការផ្តល់ សេវារដ្ឋបាល កាត់បន្ថយអំពើពុករលួយ និងបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋលើប្រព័ន្ធរដ្ឋបាល។ លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការផ្តល់មតិយោបល់ និងការរិះគន់ស្ថាបនាដើម្បីកែលំអប្រព័ន្ធ រដ្ឋបាល។ បង្វិតរដ្ឋបាលឲ្យនៅកៀកជិតប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់ សេវាឲ្យបានឆាប់រហ័សប្រកបដោយប្រសិទ្ធិភាព គុណភាព តម្លាភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[49]។

**អត្ថន័យនៃការិយាល័យច្រកចេញចូលតែមួយ**

ការិយាល័យច្រកចេញចូលតែមួយគឺជាៈ កន្លែងផ្តល់សេវារដ្ឋបាល ដែលប្រជាពលរដ្ឋត្រូវការចាំបាច់ឲ្យទាន់ពេលវេលា មានតម្លាភាព និងតាមនីតិវិធីសាមញ្ញ កន្លែងប្រមូលផ្តុំសេវារដ្ឋបាល និង នីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ កន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ និងទទួលព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ស្តីពីការផ្តល់សេវារដ្ឋបាលផ្សេងៗ និងការបង់កម្រៃសេវា ឬអាករផ្សេងៗ និងជាកន្លែងផ្តល់លទ្ធផលសម្រេចជាផ្លូវការ លើសេចក្តីស្នើរសុំដល់អតិថិជន[50]។

[49] កែវ ច័ន្ទរស្មី“ អភិបាលកិច្ចល្អខណ្ឌមានជ័យ” ឆ្នាំ២០១៤ ទំព័រទី៣២

[50] ក្រសួងមហាផ្ទៃ “ ការិយាល័យច្រកចេញចូលតែមួយ” ឆ្នាំ២០១១ ទំព័រទី៨

**២.៥.១.៣. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

លើកកម្ពស់ចលនាមហាជន ចូលរួមការពារសន្តិសុខសុវត្ថិភាពនៅក្នុងមូលដ្ឋាន ដើម្បីពង្រឹងខឿន សន្តិសុខឲ្យកាន់តែរឹងមាំ តាមរយៈការបន្តជំរុញចលនា នៃការអនុវត្តគោលនយោបាយ " ភូមិ-សង្កាត់មានសុវត្ថិភាព" ទាំងប្រាំចំនុច ឲ្យមាននិរន្តភាព និងសកម្មភាពនៅគ្រប់មូលដ្ឋានទូទាំងខណ្ឌ ព្រមទាំង ពង្រឹងវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ដើម្បីបង្ករភាពកក់ក្តៅក្នុងការរស់នៅ ការធ្វើដំណើរការដើរហើរ និងប្រកបមុខរបររបស់ប្រជាពលរដ្ឋ ក្នុងនោះយើងសង្កេតឃើញគោលនយោបាយ ៥ ចំណុច នោះរួមមានដូចជា៖ គ្មានសកម្មភាពលួចឆក់ ប្លន់ គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀន គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ រួមទាំងអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ[51]។

ចំពោះសភាការណ៍បទល្មើសព្រហ្មទណ្ឌវិញ សាលាខណ្ឌច្បារអំពៅបានយល់ថា កាលណាមានការមិនគោរពច្បាប់នៃប្រទេសមានការកើនឡើងនៅក្នុងមូលដ្ឋាន ដូចនេះវាអាចនឹងធ្វើឲ្យមាននូវភាពអនាធិបតេយ្យ អសន្តិសុខនៅក្នុងមូលដ្ឋាន ហេតុដូច្នេះហើយទើបសាលាខណ្ឌច្បារអំពៅបានខិតខំក្នុងការកាត់បន្ថយ និងព្យាយាមក្នុងការលុបបំបាត់ គឺបង្កានិងទប់ស្កាត់នូវអំពើទាំងនេះ និងបំបាត់នូវក្មេងទំនើងនៅមូលដ្ឋានស្ទើរតែគ្មាន។ តាមរយៈការចុះទៅដោះស្រាយទាន់ពេលវេលា ការដែកនូវអាវុធជាតិផ្ទុះ ការចុះយាមល្បាត និងការផ្សព្វផ្សាយពីគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពៈ

- បទល្មើសព្រហ្មទណ្ឌកើតឡើង ៣៩០លើក ស្លាប់៤៦នាក់ របួស៥៧នាក់ ឃាត់ខ្លួន៣៦១នាក់ ក្នុងនោះបទឧក្រិដ្ឋ ១៦២លើក ស្លាប់៤៦នាក់ របួស៣៤នាក់ ឃាត់ខ្លួន១៦នាក់ និងបទមជ្ឈិមកើតឡើង២២៨លើក របួស២៣នាក់ និងឃាត់ខ្លួន២៤៥នាក់។
- លទ្ធផលបង្ក្រាបបទល្មើសព្រហ្មទណ្ឌៈ បង្ក្រាបបាន៦៣២លើកបណ្តាលឲ្យស្លាប់មនុស្ស០៦នាក់ និងឃាត់ខ្លួនបាន៩៦៦នាក់ ក្នុងនោះបទឧក្រិដ្ឋបង្ក្រាបបាន៣០១លើក ឃាត់ខ្លួនបាន៥២១នាក់ បទមជ្ឈិមបង្ក្រាបបាន៣៣១លើក បណ្តាលឲ្យមនុស្សស្លាប់០៦នាក់ និងឃាត់ខ្លួន៤៤៥នាក់។

ប៉ុន្តែទោះជាមានការដាក់ចេញនូវគោលនយោបាយផ្សេងៗ ការហាមឃាត់និងការបង្ក្រាបយ៉ាងណាក៏ដោយក៏បទល្មើសនៅក្នុងមូលដ្ឋាននៃខណ្ឌច្បារអំពៅនៅតែកើតមាន គ្រាន់តែវាមានភាពតិចតួច[52]។

---

[51] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពី " ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិឃុំ មានសុវត្ថិភាព" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

[52] របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី១

### ២.៥.១.៤. ប័ណ្ណមូលនិធិសមធម៌

ប័ណ្ណមូលនិធិសមធម៌ ត្រូវបានផ្តល់ឲ្យដោយសហគមន៍លើកកម្ពស់សុខុមាលភាពប្រជាជនខណ្ឌច្បារអំពៅ ដែលត្រូវបង្កើតឡើងដោយលិខិតលេខ ០០១សលសប្រ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការសុំចុះបញ្ជីរបស់សហគមន៍។

បានផ្តល់ប័ណ្ណមូលនិធិសមធម៌ដល់ប្រជាពលរដ្ឋក្រីក្រដើម្បីទទួលសេវាព្យាបាលជម្ងឺដោយឥតបង់ប្រាក់ តាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពសរុបចំនួន៥,០៣៦គ្រួសារ។ ហើយសហគមន៍នេះមានគោលដៅសំខាន់ៗដូចជា៖ លើកស្ទួយសុខភាពប្រជាជនក្រីក្រឲ្យទទួលបានសេវាសុខភាពសាធារណៈដោយឥតបង់ប្រាក់តាមរយៈការផ្តល់ប័ណ្ណមូលនិធិសមធម៌ដោយសហការជាមួយអង្គការនានា ដៃគូរអភិវឌ្ឍន៍សនិងសប្បុរសជន លើកទឹកចិត្តបុគ្គលិកសុខាភិបាល ដើម្បីផ្តល់សេវាឲ្យបានល្អប្រសើរដល់ប្រជាពលរដ្ឋ ធានាឲ្យអ្នកក្រីក្របានប្រើប្រាស់សេវាសុខភាពដែលមានគុណភាព បង្កើតយន្តការជាប្រព័ន្ធ និងពេញលេញមួយដែលគ្រប់គ្រងដោយមានរចនាសម្ព័ន្ធដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងការគាំពារសុខមាលភាពសង្គម បង្កើនការប្រើប្រាស់សេវាសុខាភិបាលដោយពេញចិត្ត និងការចូលរួមរបស់ប្រជាជនក្រីក្រទូទៅក្នុងប្រព័ន្ធ សុខាភិបាលសាធារណៈនៃសាលាខណ្ឌច្បារអំពៅ និងផ្តល់ឱកាសជូនប្រជាពលរដ្ឋក្រីក្រលើកសំណូមពរពីការខ្វះខាត និងចូលរួមផ្ទាល់ដើម្បីធ្វើឲ្យជីវភាពសុខុមាលភាពប្រសើរឡើង[53]។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ សហគមន៍មានទិសដៅរបស់ខ្លួនដូចខាងក្រោម ៖ បង្កើមអត្រប្រើប្រាស់ និងជំនឿលើមូលដ្ឋានសុខាភិបាលសាធារណៈ រួមចំណែកកែលម្អគុណភាពនៃប្រព័ន្ធសុខាភិបាលសាធារណៈ ផ្តល់ជូនអ្នកក្រីក្រដើម្បីទទួលបាននូវសេវាសាធារណៈសហការល្អជិតស្និទ្ធ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ការិយាល័យសុខាភិបាល ខណ្ឌ មន្ទីរពេទ្យ អង្គការនានា ដៃគូរអភិវឌ្ឍន៍ និងសប្បុសជន ព្រមទាំងស្ថាប័នពាក់ព័ន្ធ ចុះអង្កេតកំណត់ អត្តសញ្ញាណកម្មប្រជាជនក្រីក្រសម្របសម្រួលការទំនាក់ទំនងក្រុមប្រឹក្សាសង្កាត់ មន្ទីរពេទ្យ និង សហគមន៍ និងគៀងគររកមូលនិធិពីអង្គការនានា ដៃគូអភិវឌ្ឍន៍ និងសប្បុរសជន[54]។

### ២.៥.១.៥. សេវាសុខាភិបាល

ការងារការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាសាក់៖

- ពិនិត្យជម្ងឺទូទៅជូនប្រជាពលរដ្ឋបានចំនួន ២៧,៦៦៥នាក់
- ចាក់ថ្នាំបង្ការពារ០៩មុខ ដល់កុមារអាយុក្រោម០១ឆ្នាំបានចំនួន១២,៣៣៣នាក់

[53] ប្រការ៤ នៃលក្ខន្តិកៈសហគមន៍លើកកម្ពស់សុខុមាលភាពប្រជាជនខណ្ឌច្បារអំពៅ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១
[54] ប្រការ៥ នៃលក្ខន្តិកៈសហគមន៍លើកកម្ពស់សុខុមាលភាពប្រជាជនខណ្ឌច្បារអំពៅ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១

- ពិនិត្យផ្ទៃពោះបានចំនួន ១០,១៨៥នាក់
- ស្ត្រីសម្រាលកូនបានចំនួន ១,៨៥៥នាក់
- ពន្យាកំណើតបាន ២២,៦៣៥នាក់
- ស្ត្រីចាក់ថ្នាំTTមានផ្ទៃពោះបាន ៥,៦៣៩នាក់
- ផ្តល់ថ្នាំជីវជាតិA ទារកអាយុ ៦ដល់១១ខែ បាន១៩៣នាក់ និងទារកអាយុ១២ដល់៥៩ខែ បាន ១៨៩នាក់
- ពិនិត្យអេកូសាស្ត្របាន ៨៣២នាក់
- បានចេញរថយន្តគិលានសង្គ្រោះបាន ៧០៦លើក

– អ្នកជម្ងឺដែលទទួលបានសមធម៌បានមកពិនិត្យ និងព្យាបាលនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកមានជ័យរួមមាន: ពិគ្រោះជម្ងឺនៅក្រៅចំនួន ២,០៨៤ករណី សម្រាកពេទ្យចំនួន៨៩០ករណី និងពិគ្រោះជម្ងឺក្រៅមណ្ឌលសុខភាពច្បារអំពៅ ៣,៨៣៨ករណី មណ្ឌលសុខភាពនិរោធ ១,៥០៣ករណី មណ្ឌលសុខភាពព្រែកឯង ១,៩១១ករណី មណ្ឌលសុខភាពក្បាលកោះ ៦៧៩ករណី មណ្ឌលសុខភាពព្រែកថ្មីបាន ៩៦៥ករណីមណ្ឌលសុខភាពចាក់អង្រែចំនួន១,១០៧ករណី និងមណ្ឌលសុខភាពស្ទឹងមានជ័យ ២,៨៣៤ករណី សរុបរួម ១៥,៣១១ករណី[55]។លទ្ធផលការផ្តល់សេវាសុខាភិបាលជូនកម្មករ/និយោជិតក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធនិងមន្ត្រីសាធារណៈនៅ មូលដ្ឋានសុខាភិបាលក្នុងខណ្ឌច្បារអំពៅ

[55] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌច្បារអំពៅប្រចាំឆ្នាំ២០១៨ ទំព័រទី១៥៨

| ប្រភេទ | ប្រភេទទទួលសេវា | មន្ទីរពេទ្យបង្អែកមានជ័យ | មណ្ឌលសុខភាពច្បារអំពៅ | មណ្ឌលសុខភាពនិរោធ | មណ្ឌលសុខភាពព្រែកប្រា | មណ្ឌលសុខភាពក្បាលកោះ | មណ្ឌលសុខភាពព្រែកថ្មី | សរុប |
|---|---|---|---|---|---|---|---|---|
| កម្មករ-កម្មការិនី/និយោជិកក្នុងប្រព័ន្ធ | ចំនួនស្ត្រីសម្រាល | 38 | 0 | 7 | 2 | 3 | 9 | 59 |
| | ចំនួនពិគ្រោះជំងឺក្រៅ | 725 | 384 | 978 | 191 | 299 | 351 | 2,928 |
| | ចំនួនសម្រាកពេទ្យ | 52 | 0 | 0 | 0 | 0 | 0 | 52 |
| កម្មករ-កម្មការិនី/និយោជិកក្រៅប្រព័ន្ធ | ចំនួនស្ត្រីសម្រាល | 10 | 0 | 0 | 0 | 0 | 1 | 11 |
| | ចំនួនពិគ្រោះជំងឺក្រៅ | 80 | 77 | 373 | 32 | 58 | 119 | 739 |
| | ចំនួនសម្រាកពេទ្យ | 7 | 0 | 0 | 0 | 0 | 0 | 7 |
| មន្ត្រីសាធារណៈ | ចំនួនស្ត្រីសម្រាល | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | ចំនួនពិគ្រោះជំងឺក្រៅ | 28 | 56 | 15 | 19 | 48 | 72 | 238 |
| | ចំនួនសម្រាកពេទ្យ | 12 | 0 | 0 | 0 | 0 | 0 | 0 |
| សរុប | | 952 | 517 | 1,373 | 244 | 408 | 552 | 4,046 |

### ២.៥.១.៦. ការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន

ការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានៈ

| ល.រ | ឈ្មោះសង្កាត់ | ចំនួនខ្សែ | ផ្ទៃក្រឡា(ម$^{២}$) | តំលៃសរុប | ថវិកា៥០% |
|---|---|---|---|---|---|
| ការកសាងផ្លូវចាក់បេតុង ឬស្បី | | | | | |
| ១ | សង្កាត់និរោធ | ០៦ | ៥,៤៧៦ | ២៤៣,៩៩៧,០០០រៀល | ១២១,៧៩៨,៥០០រៀល |
| ២ | សង្កាត់ច្បារអំពៅទី១ | ០៨ | ១៣,២១៤ | ៥៦៣,៤៨០,០០០រៀល | ២៨១,៧៤០,០០០រៀល |
| ៣ | សង្កាត់ច្បារអំពៅទី២ | ១១ | ៦,០៤៧ | ៣៧៨,៧៥៨,៥០០រៀល | ៣២៩,២៥៨,៥០០រៀល |
| ៤ | សង្កាត់ព្រែកប្រា | ០៣ | ១០,៦៤០ | ៤៤៧,៥១២,៥០០រៀល | ១៦០,១៥៨,៥០០រៀល |
| ៥ | សង្កាត់ព្រែកថ្មី | ០៩ | ៦,៧៤៦ | ៤១៤,២៦៥,០០០រៀល | ២០៧,១៣២,៣០០រៀល |
| ៦ | សង្កាត់ក្បាលកោះ | ០២ | ១២,៦៨៤ | ១,១១០,១១៧,០០០រៀល | ៥៥៥,០៥៨,៥០០រៀល |
| ៧ | សង្កាត់ព្រែកឯង | ១៧ | ៣២,២០៩ | ១,៧ ៤៩,១០៨,៥០០រៀល | ៨៧៤,៧០៥,១០០រៀល |
| ៨ | សង្កាត់វាលស្បូវ | ២០ | ៣៨,៤៤៨ | ២,៧២០,២០៨,៤០០រៀល | ១,៣៦០,១០៤,៦០០រៀល |
| សរុប | | ៧៦ | ១២៥,៤៦៤ | ៧,២៥៣,៩៥១,៩០០រៀល | ៨៨៩,៨៩៦,០០រៀល |

| ការងារកសាងប្រព័ន្ធលូ | | | | | |
|---|---|---|---|---|---|
| ១ | សង្កាត់និរោធ | ០១ | ១១៣ | ១៣,៨៣៥,៧០០ | ៦,៧១៧,៨៥០រៀល |
| ២ | សង្កាត់ច្បារអំពៅទី១ | ០ | ០ | ០ | ០រៀល |
| ៣ | សង្កាត់ច្បារអំពៅទី២ | ០៣ | ៧១៤ | ១១៥,៤៥៣,៨០០រៀល | ៥៧,៧២៦,៩០០រៀល |
| ៤ | សង្កាត់ព្រែកប្រា | ០៤ | ១១៩០ | ១៨២,២៨៦,០០០រៀល | ៩១,១៤៣,០០០រៀល |
| ៥ | សង្កាត់ព្រែកថ្មី | ០៣ | ៧២៧ | ៨៣,៤៥៩,៦០០រៀល | ៤១,៧២៩,៨០០រៀល |
| ៦ | សង្កាត់ក្បាលកោះ | ០១ | ១៥០ | ២៤,២២៥,០០០រៀល | ១២,១២៧,៥០០រៀល |
| ៧ | សង្កាត់ព្រែកឯង | ០៣ | ១០២១ | ១៦៥,០៩៥,៧០០រៀល | ៨២,៥៤៧,៨៥០រៀល |
| ៨ | សង្កាត់វាលស្បូវ | ០៦ | ១៩២៧ | ៣១១,៥៩៥,៩០០រៀល | ១៥៥,៧៩៧,៩៥០រៀល |

__ប្រភព__៖ *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

### ២.៥.២. ការចូលរួមរបស់ប្រជាពលរដ្ឋ

នៅក្នុងប្រទេសដែលប្រកាន់យកនូវរបបប្រជាធិបតេយ្យ គឺមិនអាចខ្វះបានទេនូវការចូលរួមរបស់ប្រជាពលរដ្ឋបានទេ ព្រោះថាប្រជាពលរដ្ឋគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការជួយជម្រុញនូវការកសាង និងអភិវឌ្ឍន៍សង្គមជាតិឲ្យរីកចម្រើនក៏ប៉ុន្តែការចូលរួមរបស់ប្រជាពលរដ្ឋដល់កម្រិតណានោះ គឺវាអាស្រ័យទៅលើច្បាប់ដែលបានកំណត់នូវនៃសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមក្នុងសកម្មភាពសង្គម ហើយចំណុចទាំងអស់នេះហើយគឺជាមូលដ្ឋានគ្រឹះក្នុងការបង្កើតឲ្យមានអភិបាលកិច្ច និងឆ្ពោះទៅរកប្រជាធិបតេយ្យពិតៗទើបសាលាខណ្ឌផ្តល់ឲ្យប្រជាពលរដ្ឋនូវការចូលរួមមួយដូចជា៖

#### ២.៥.២.១. ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត៖

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
| ១ | ប្រជាពលរដ្ឋដែលបានចុះបញ្ជីថ្មី | ៦,៨៥៦ | ៦,៧៧០ | ២១,៥៨១ | ២៥,៥៩៧ | ១,៨២៨ | ៦២,៦៣២ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ១,៧៣៩ | ៤,២១៩ | ២,៧៨១ | ៤,៤៦៣ | ១,៤៦៣ | ១៤,៦៣០ |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត(ចាស់ និងថ្មី) | ១៩៩,៥៤៤ | ១៩៨,១០៣ | ១៩៧,៣៧៨ | ២០១,៥៧៥ | ២០២,៤១៩ | |

__ប្រភព__៖ *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

**២.៥.២.២. ការងាររៀបចំវេទិកាសាធារណៈ**

ដើម្បីបង្ករលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងការបញ្ចេញមតិ និងបានរៀបចំវេទិការសាធារណៈបានចំនួន៥០៤លើក មានមនុស្សចូលរួមចំនួន៦៦២៦៥នាក់។

**២.៥.២.៣. ការចូលរួមរបស់ប្រជាពលរដ្ឋជានារីក្នុងមូលដ្ឋាន**

❖ ការងារអប់រំផ្សព្វផ្សាយ

- ផ្សព្វផ្សាយទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរ ការរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារ ៦៧លើក អ្នកចូលរួមសរុបចំនួន៣,៣៥៥នាក់ ស្រី១,៩៤៦នាក់។
- ផ្សព្វផ្សាយសីលធម៌សង្គម តំលៃស្ត្រី និងគ្រួសារខ្មែរ ចំនួន៥០លើក អ្នកចូលរួមសរុប ១,៨០៦នាក់ ស្រី១,១៣៥នាក់។
- អប់រំផ្សព្វផ្សាយស្តីពីសុខភាពស្ត្រីនិងកុមារ ចំនួន៨២លើក អ្នកចូលរួមសរុប២,៩៩៤នាក់ ស្រី ១,៩៧១នាក់។
- ផ្សព្វផ្សាយឲ្យស្ត្រីពិនិត្យសុខភាពរកជំងឺមហារីកមាត់ស្បូននៅមណ្ឌលសុខភាព ដើម្បីព្យាបាលដោយឥតគិតថ្លៃ បានចំនួន២៥នាក់ក្នុងនោះបាញ់កាំរស្មីចំនួន៤នាក់ នៅសង្កាត់ព្រែកថ្មី។
- ផ្សព្វផ្សាយសារៈសំខាន់នៃការចុះសំបុត្រអត្រានុកូលដ្ឋាន អ្នកចូលរួមសរុបចំនួន៧៩២នាក់ ស្រី៦០៥នាក់។
- ផ្សព្វផ្សាយផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន អ្នកចូលរួមសរុបចំនួន៦៨៣នាក់ ស្រី ៦៦៨នាក់។
- ផ្សព្វផ្សាយស្តីពីគ្រោះមហន្តរាយ ដល់ប្រជាពលរដ្ឋនៅភូមិស្វាយតាអុក១ អ្នកចូលរួមចំនួន៣៧នាក់។
- ផ្សព្វផ្សាយស្តីពីការប្រែប្រួលអាកាសធាតុ និងភាពបន្សាំដល់ប្រជាពលរដ្ឋនៅភូមិដើមចាន់ អ្នកចូលរួមចំនួន៣០នាក់ ស្រី២៦នាក់។
- ផ្សព្វផ្សាយដល់មាតាបិតាសិស្សឲ្យតាមដានការសិក្សារបស់កូននៅសាលាព្រែកប្រាក្រោម អ្នកចូលរួមសរុបចំនួន៤៩នាក់។
- ផ្សព្វផ្សាយស្តីពីហានិភ័យគ្រោះទឹកជំនន់ដល់ប្រជាពលរដ្ឋនៅតាមដងទន្លេឲ្យមានការប្រុងប្រយ័ត្ន និងទុកដាក់ឯកសារសំខាន់ៗនិងសម្ភារៈចាំបាច់ឲ្យបានត្រឹមត្រូវ អ្នកចូលរួមសរុប ៣២៤នាក់ ស្រី២៧៧នាក់។

- នារីសង្កាត់និរោធ និងវាលស្បូវសហការជាមួយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ មន្ទីរពេទ្យបង្អែកមានជ័យនិងមណ្ឌលសុខភាព ចុះចាក់ថ្នាំបង្ការជម្ងឺកញ្ជ្រិលដល់កុមារក្រោម អាយុ ២-៦ឆ្នាំ ក្នុងសង្កាត់និរោធ បានចំនួន៣០៦នាក់។ ចែកថ្នាំទឹកស៊ីជើង និងថ្នាំការពារ ជម្ងឺផ្សេងៗបានចំនួន២៥០នាក់។ ផ្តល់ថ្នាំអាប៉ែតដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកលិច នៅភូមិក្តីតាកុយ សង្កាត់វាលស្បូវ បានចំនួន៣៥៦នាក់។
- នារីសង្កាត់ព្រែកប្រា វាលស្បូវ និងក្បាលកោះ សហការជាមួយអង្គការ CODO ចុះអប់រំផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់នៃគ្រឿងញៀនចំនួន៥លើក អ្នកចូលរួមសរុបចំនួន១២៥នាក់ស្រី៨៩នាក់។

❖ ការងារបណ្តុះបណ្តាល

- នារីខណ្ឌបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពី៖
  - វគ្គបណ្តុះបណ្តាលស្តីពីគោលគំនិតយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ រយៈពេល៣ថ្ងៃ នៅខេត្តតាកែវ រៀបចំដោយក្រសួងកិច្ចការនារី។
  - វគ្គបណ្តុះបណ្តាលស្តីពី ការងារគ្រប់គ្រងរដ្ឋបាល រយៈពេល៣ថ្ងៃ នៅខេត្តកំពង់ចាម រៀបចំដោយក្រសួងកិច្ចការនារី។
  - វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងហានិភ័យនិងគ្រោះមហន្តរាយ និងប្រែប្រួលអាកាសធាតុរយៈពេល៤ថ្ងៃនៅខេត្តសៀមរាបរៀបចំដោយអង្គការទស្សនៈពិភពលោក។
  - វគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ចំនួន២វគ្គ រយៈពេល៨ថ្ងៃ នៅសណ្ឋាគារភ្នំពេញអេរ៉ា រៀបចំដោយអង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា។
  - វគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងការចំណាយលើការងារសេវាសង្គមសង្កាត់ រៀបចំដោយសាលារាជធានីភ្នំពេញ។
- នារីសង្កាត់ទាំង៨ បានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាមួយក្រសួងនិងមន្ទីរពាក់ព័ន្ធ អាជ្ញាធរដែនដី និងអង្គការដៃគូរ បានចំនួន១៤លើក លើប្រធានបទរួមមាន៖
  - វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចនានារយៈពេល៣ថ្ងៃ នៅខេត្តកំពងចាម រៀបចំដោយក្រសួងកិច្ចការនារី។
  - វគ្គបណ្តុះបណ្តាលស្តីពី ការធ្វើសមាហរណកម្មកុមារទោសបាតមន៍ប្រកបដោយសុវត្ថិភាព រៀបចំដោយអង្គការ Unicef។
  - វគ្គបំប៉នស្តីពី ការកំណត់មាតិកាថវិកាលិខិតយុត្តិការការចំណាយសម្រប់ទូទាត់សេវាសង្គម នៅសាលារាជធានីភ្នំពេញ។

- វគ្គបណ្ដុះបណ្ដាលស្ដីពីកិច្ចការពារកុមារងាយរងគ្រោះ និងធ្វើសមាហរណកម្មកុមាររស់នៅមណ្ឌល ប្រមូលផ្ដុំក្នុងគ្រួសារនិងសមាគម រៀបចំដោយនាយកដ្ឋានកិច្ចការប៉ុស្តិ៍រដ្ឋបាល។
- វគ្គបណ្ដុះបណ្ដាលស្ដីពីការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រប្រជុំទី១២ រៀបចំដោយមន្ទីរផែនការ។
- វគ្គបណ្ដុះបណ្ដាលស្ដីពីភាពធន់របស់សហគមន៍ដើម្បីកុមាររៀបចំដោយអង្គការមិត្តសំឡាញ់។
- សិក្ខាសាលាស្ដីពីការអន្តរាគមន៍ជួយជនរងគ្រោះដោយករណីអំពើហិង្សាក្នុងគ្រួសារ រៀបចំដោយអង្គការសមត្ថភាពខ្ញុំ។
- សិក្ខាសាលាស្ដីពីគម្រោងការពារកុមារពីអាយុ៥-១៧ឆ្នាំ រៀបចំដោយអង្គការសមត្ថភាពខ្ញុំ ទស្សនៈពិភពលោក។
- សិក្ខាសាលាស្ដីពីការកាត់បន្ថយគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន រៀបចំដោយអង្គការមិត្តសំឡាញ់។
- សិក្ខាសាលាផ្សព្វផ្សាយស្ដីពី សន្តិសុខស្បៀងនិងអាហាររូបត្ថម្ភ រៀបចំដោយអង្គការហេឡែនខេល័រ។
- សិក្ខាសាលាផ្សព្វផ្សាយស្ដីពី គ្រួសាររីករាយ រៀបចំដោយអង្គការទស្សនៈពិភពលោក។

❖ កិច្ចអន្តរាគមន៍ជួយជនរងគ្រោះ(ករណីអំពើហិង្សាក្នុងគ្រួសាររំលោភសេពសន្ថវៈនិងជួញដូរស្ត្រីនិងកុមារ)

- បានសម្របសម្រួល ករណីអំពើហិង្សាក្នុងគ្រួសារ ២១ករណីនៅសង្កាត់ច្បារអំពៅទី២និរោធ ព្រែកប្រា វាលស្បូវ ក្បាលកោះ និងព្រែកថ្មី ក្នុងនោះ សះជាគ្នាវិញ ១៩ករណីបញ្ជូនទៅអធិការដ្ឋាននគរបាលខណ្ឌ ៣ករណី។
- បានសម្របសម្រួលកណីលែងលះ ១៥ករណី ក្នុងនោះ១១ករណី ភាគីទាំង២ឯកភាពធ្វើកិច្ចសន្យាលែងលះគ្នានៅថ្នាក់សង្កាត់ (ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍)។
- ករណីរំលោភសេពសន្ថវៈ៣ករណី នៅសង្កាត់ច្បារអំពៅទី២ ព្រែកឯងនិងក្បាលកោះ ជនរងគ្រោះអាយុ៩ ១២ និង២១ឆ្នាំ មានអង្គការដៃគូជួយផ្នែកសេវាផ្លូវច្បាប់ សុខភាព សិក្សា និងស្បៀងអាហារ។ ជនល្មើសបញ្ជូនទៅអធិការដ្ឋាននគរបាលខណ្ឌចាត់ការតាមនីតិវិធីច្បាប់។
- បានបញ្ជូនកុមារ២នាក់រងគ្រោះអំពើហិង្សាពីលោក**កាន់ម៉ន**ទៅមណ្ឌលមន្ទីរសង្គមកិច្ច[56]។

[56] របាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ២០១៨ របស់ការិយាល័យកិច្ចការនារី

**២.៥.២.៤. ការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- លក់ផ្តាច់បានចំនួន ២,៨០៥ប័ណ្ណ
- អំណោយផ្តាច់ចំនួន ៧៦ប័ណ្ណ
- ស្នើសុំទុតិយតាចំនួន ១៦ប័ណ្ណ
- បំបែក អំណោយផ្តាច់ចំនួន ២៥ប័ណ្ណ
- បំបែក លក់ផ្តាច់ចំនួន ១១២ប័ណ្ណ
- ស្នើសុំបង្រួមក្បាលដីចំនួន ១០ប័ណ្ណ
- ស្នើសុំចុះបញ្ជីដាច់ដោយដុំចំនួន ១៩៦ប័ណ្ណ
- បំបែកក្បាលដីខ្លួនឯងចំនួន ៣៥ប័ណ្ណ
- បានចូលរួមវាស់វែងការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី ចំនួន៨៦៣ ឯកសារ។
- បានរៀបចំបែបបទស្នើសុំសាងសង់តាមរយៈការិយាល័យច្រកចេញចូលតែមួយចំនួន៣៦ ទីតាំង។
- បានរៀបចំបែបបទស្នើសុំសាងសង់ពីរដ្ឋបាលរាជធានីភ្នំពេញចំនួន១៧ទីតាំង[57]។

**២.៥.៣. ការពង្រឹងនីតិរដ្ឋ**

នីតិរដ្ឋក្នុងន័យនេះគឺផ្តោតសំខាន់ទៅលើ ឯកសារក្របខណ្ឌច្បាប់ ការអនុវត្តន៍ច្បាប់ដោយមិនលំអៀង ការការពារសិទ្ធិមនុស្ស តុលាឯករាជ្យនិងយុត្តិធម៌ ពង្រឹងសមត្ថកិច្ច ការអនុវត្តន៍ច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។ ទន្ទឹមនិងនេះដែរមន្ត្រីគ្រប់រូបនៅក្នុងសាលាខណ្ឌច្បារអំពៅ បានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងការជួយពង្រឹងនីតិរដ្ឋក្នុមូលដ្ឋានរបស់ខ្លួន តាមរយៈការយកច្បាប់រដ្ឋជាគោលក្នុងការសម្រេចអ្វីមួយ[58]។

**២.៥.៤. ការជម្រុញឲ្យមានតម្លាភាព និងការឆ្លើយតប**

នៅក្នុងសាលាខណ្ឌមួយៗ គឺសំខាន់ណាស់ទៅលើ តម្លាភាព និងការឆ្លើយតប គឺជាកត្តាសំខាន់មួយសម្រាប់សបញ្ជាក់ពីភាពស្អាតស្អំនៃការធ្វើការសម្រេចចិត្តដោយគោរពទៅតាមច្បាប់ និងលិខិតបទដ្ឋាននានានិងផ្សព្វផ្សាយជាចំហរតាមរយៈប្រព័ន្ធសមស្របមួយទៅកាន់ក្រុមមនុស្ស ដែលអាច និងទទួលរងផលប៉ះពាល់នោះបានដឹងឮ និងដើម្បីបញ្ចៀសការរំលោភបំពានច្បាប់ និងរំលោភអំណាចណាមួយ។ និងចំពោះការឆ្លើយតបនោះ គឺសាលាខណ្ឌច្បារអំពៅក៏បានយល់ថាការឆ្លើយតបពិតប្រាកដនៅ

[57] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌច្បារអំពៅប្រចាំឆ្នាំ២០១៨ ទំព័រទី១៧៨

[58] កែវ រស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី៣៧

ក្នុងគោលការណ៍អភិបាលកិច្ចល្អនេះត្រូវទាមទារឲ្យស្ថាប័ន និងអង្គភាពប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងបុគ្គលដែលពាក់ព័ន្ធទាំងអស់ឲ្យស្មើរភាពគ្នា ហើយការឆ្លើយតបនេះត្រូវស្ថិតក្នុងពេលវេលាមួយសមស្រប និងសមហេតុផល។ ម្យ៉ាងវិញទៀតសាលាខណ្ឌក៏មានកាតព្វកិច្ចប្រាប់ពីមូលហេតុ និងបញ្ហាទាំងឡាយដែលអាចឲ្យសេចក្តីសម្រេចនោះជាប់គាំង និងត្រូវឈានទៅរកការស្វែងរកនូវដំណោះស្រាយ។ ដូចជាក្នុងករណីខណ្ឌច្បារអំពៅ និងសង្កាត់ដែលជាសេនាធិការនៅពេលដែលប្រជាពលរដ្ឋម្នាក់មានទំនាស់ ឬ មានតម្រូវការអ្វីមួយក្នុងមូលដ្ឋាន គាត់បានដាក់សំណើ ឬពាក្យបណ្តឹង គឺសង្កាត់តែងតែធ្វើការឆ្លើយតបដោយការដោះស្រាយ ជាការសម្រុះសម្រួល ផ្សះផ្សាយ ឬនីតិវិធីផ្សេងៗទៅពួកគាត់ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព។ចំពោះការឆ្លើយតបនេះ ខណ្ឌច្បារអំពៅបានបង្កើតនូវសមិទ្ធិផលនៃផែនការ និងសកម្មភាពជាច្រើនដូចជា៖ សាលាខណ្ឌបានចុះទៅសម្របសម្រួលបណ្តឹងបរិស្ថានចប់ចំនួន៧០មូលដ្ឋាន និងតាមរយៈផ្តល់ការកសាងសមត្ថភាពដល់ ក្រុមប្រឹក្សា និងផ្តល់ការគាំទ្រអំពីការលើកកម្ពស់អភិបាលកិច្ចល្អ កសាងការយល់ដឹងរបស់សាធារណៈជនទាក់ទងនិងសិទ្ធិរបស់ប្រជាពលរដ្ឋ ពិនិត្យតាមដានក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីធានាឲ្យបានថាសេចក្តីសម្រេចត្រូវបានផ្សព្វផ្សាយ ហើយឯកសារត្រូវបើកឲ្យសាធារណៈជន ពិនិត្យមើលនៅសាលាឃុំ/សង្កាត់ ជម្រុញការញ្ជូនប្រជាពលរដ្ឋទៅក្នុងគណៈកម្មាធិការនានា និងបង្កើតប្រព័ន្ធទទួលស្គាល់ តួនាទីគំរូ របស់ឃុំ សង្កាត់នៅក្នុងអភិបាលកិច្ចល្អ[59]។

ការជម្រុញឲ្យមានតម្លាភាព និងការឆ្លើយតបៈ

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
| ១ | ករណីដែលបានដោះស្រាយឬសម្រុះសម្រួលរួច | ៥៤០ | ៥០៩ | ៥២៧ | ៤៨០ | ៥៤១ | ២,៥៩៧ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ៤៥ | ៣៦ | ២៦ | ២៧ | ៤៣ | ១៧៦ |

*<u>ប្រភព</u>៖ របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

**កិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១៤៤ | ១៤៤ | ១៤៤ | ១៤៤ | ១៤៤ | ៧២០ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ២២ | ១៧ | ៣២ | ៣៦ | ២៨ | ១៣៥ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 0 | 0 | 0 | 0 | ២ | ២ |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក | ១៥៦ | ១៤៧ | ១៤១ | ១៣៥ | ១២៨ | ៦៩៧ |

[59] កែវ រស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី៣៩

*ប្រភព៖ របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

### ២.៥.៥. ការទទួលខុសត្រូវ និងគណនេយ្យភាព

សាលាខណ្ឌច្បារអំពៅ បានយល់ពីសារៈសំខាន់នៃភាពទទួលខុសត្រូវក្នុងការងារចំពោះមុខសាធារណៈជនទូទៅ និងចំពោះមុខថ្នាក់ដឹកនាំ។ ហេតុនេះហើយសាលាខណ្ឌច្បារអំពៅមានគោលការណ៍ច្បាស់លាស់ក្នុងការងារនិងក្នុងការសម្រេចចិត្តធ្វើនូវកិច្ចការអ្វីមួយ។ ក្របខណ្ឌច្បាប់វិមជ្ឈការ ជាការផ្តោតទៅលើការពង្រឹងអភិបាលកិច្ច ដែលមានគណនេយ្យភាព និងតម្លាភាពរបស់ក្រុមប្រឹក្សា។ ការរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ការរៀបចំថវិកា របស់សង្កាត់ ការដេញថ្លៃគម្រោង និងការគ្រប់គ្រងគម្រោង សុទ្ធតែបានអនុវត្តន៍តាមនីតិវិធីដែលមានតម្លាភាព ការចូលរួមគណនេយ្យភាព ដោះស្រាយបាននូវសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពកលរដ្ឋនៅមូលដ្ឋាននិងមានប្រសិទ្ធិភាព។

រាល់ការចំណាយទាំងអស់ ព្រមទាំងចំណាយខាងរដ្ឋបាល និងកាអភិវឌ្ឍន៍ក្រុមប្រឹក្សាសង្កាត់ បានរៀបចំជារបាយការណ៍ប្រកបដោយតម្លាភាព។ ការប្រើប្រាស់ក្តារព័ត៌មាន ការផ្សព្វផ្សាយអំពីរបាយការណ៍ចំណាយ ការអនុវត្តន៍ភារកិច្ច និងការផ្តល់សេវាសាធារណៈនានាដែលប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មាន និងត្រូវបានយកចិត្តទុកដាក់ពីក្រុមប្រឹក្សាសង្កាត់ទាំង៨។ ដើម្បីពង្រឹងគណនេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានបំពាក់ប្រអប់សំបុត្រគណនេយ្យភាពនៅតាមទីស្នាក់ការសង្កាត់ទាំង ០៨ ក្នុងគោលដៅដើម្បីប្រមូលព័ត៌មានពីភាពមិនប្រក្រតីនានា ដែលអាចកើតមាននៅក្នុងការអនុវត្តគម្រោងមូលនិធិសង្កាត់នីមួយៗ[60]។

[60] កែវ រស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី៤០

# ជំពូកទី៣៖ លទ្ធផលនៃការអនុវត្តការងារ និងទិសដៅសកម្មភាពនាពេលអនាគត

ដើម្បីឲ្យការស្រាវជ្រាវមានលក្ខណៈកាន់តែប្រសើរ និងកាន់តែមានភាពច្បាស់លាស់ គឺយើងមិនត្រឹមតែស្រាវជ្រាវទៅលើឯកសារ និងរបាយការណ៍ដែលមានក្នុងសាលាខណ្ឌតែប៉ុណ្ណោះទេ គឺយើងធ្វើការសាកសួរផ្ទាល់ពីសំណាក់ ប្រជាពលរដ្ឋ មន្ត្រីក្នុងសាលាខណ្ឌផងដែរ។

## ៣.១. ការគិតគូរពីសេវាសាធារណៈ

សេវាសាធារណៈ គឺជាសេវាមួយដែលមានសារៈសំខាន់ ចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដូចគ្នានេះដែរ មានសេវាជាច្រើនដែលស្ថិតនៅក្នុងចង្កោមនៃសេវាសាធារណៈនេះ ប៉ុន្តែយើងបានយកមកលើកឡើងតែពីសេវាកម្មមួយចំនួន ដែលជាសេវាអាទិភាពដែលប្រជាពលរដ្ឋតែងតែមកទទួលសេវានេះជាញឹកញាប់នៅមូលដ្ឋានតែប៉ុណ្ណោះ។

### ៣.១.១. សេវាអត្រានុកូលដ្ឋាន

ជាការពិតណាស់សេវាអត្រានុកូលដ្ឋាន ជាសេវាមួយដែលផ្តល់ជូនតាមរយៈចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ចំណែកស្មៀន និងមន្ត្រីសង្កាត់ ជាជំនួយការ។ សំបុត្រអត្រានុកូលដ្ឋានដែលមន្ត្រីបានផ្តល់ឲ្យរួមមាន៖ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណៈភាព។ ក្នុងករណីនេះដែរយើងបានធ្វើការសាកសួរ ទៅលើមន្ត្រីក្នុងខណ្ឌច្បារអំពៅ ដែលទើបនឹងកាត់ចេញពីខណ្ឌមានជ័យចំនួន៨សង្កាត់[61]។ ក្នុងនោះដែររួមមាន៖ សង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់ព្រែកប្រា សង្កាត់និរោធ សង្កាត់ព្រែកថ្មី សង្កាត់ក្បាលកោះ សង្កាត់ព្រែកឯង សង្កាត់វាលស្បូវ[62]។

សេវាអត្រានុកូលដ្ឋាន៖

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
| ១ | សំបុត្រកំណើត | ៣,០៩២ | ៣,៣៩៥ | ៣,២២៦ | ៣,៤៥៦ | ៤,០៧៨ | ១៧,១៧៩ |
| ២ | សេចក្តីបញ្ជាក់កំណើត | ៤,៦៨៥ | ៥,២១៨ | ៥,០០១ | ៥,២១៨ | ៥,០៩៩ | ២៥,២២១ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១,៥០៧ | ១,៧៣៨ | ១,៦៥៧ | ២,២៦៣ | ១,៧០៧ | ៨,៨៧២ |
| ៤ | សេចក្តីចម្លងបញ្ជាក់សំបុត្រកំណើត | ១,៨៤៥ | ២,១៧៧ | ២,១៩៧ | ២,៤៤៣ | ១,៩៨៤ | ១០,៦៤៦ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ១,៤៣៤ | ១,៣២៧ | ១,៤៦៦ | ១,៤១៦ | ១,៣៣៦ | ៦,៩៧៩ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៦៥៩ | ៦៨០ | ៧៣៩ | ១,០៣៣ | ៦០៩ | ៣,៧២០ |
| ៧ | សំបុត្រមរណភាព | ៥៣១ | ៥៨៦ | ៦០៩ | ៧៩៨ | ៧៥០ | ៣,២៨៤ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៤៤០ | ៤០៧ | ៦៣០ | ៧៥១ | ៦៣០ | ២,៨៥៨ |

[61] កែវ ច័ន្ទរស្មី "អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី៤៣

[62] អនុក្រឹតលេខ ៥៧៩ អនក្រ. បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៣

<u>**ប្រភព**</u>៖ *របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

របាយការណ៍ខាងលើនេះបានបង្ហាញពី សមិទ្ធផលការងាររបស់សង្កាត់នីមួយៗក្នុងសាលាខណ្ឌច្បារអំពៅក្នុងអាណត្តិទី១ដែលបានធ្វើកន្លងមក ស្តីពីការងារអត្រានុកូលដ្ឋាន។ បើយោងទៅលើ តារាងខាងលើនេះបានបង្ហាញឲ្យយើងឃើញថា ប្រជាពលរដ្ឋមានតម្រូវការទៅលើសំបុត្របញ្ជាក់កំណើតមានចំនួនច្រើនជាងសំបុត្រអត្រានុកូលដ្ឋានផ្សេងៗ និងមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ។ ផ្ទុយទៅវិញ សេចក្តីសំបុត្រមរណៈភាពមានចំនួនតិចជាងគេ ប៉ុន្តែមានការកើនឡើងជាលំដាប់រៀងរាល់ឆ្នាំផងដែរ។ ដូចនេះ បានសបញ្ជាក់ពីតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាងច្រើនលើសលុបក្នុងការទទួលសេវា បើប្រៀបធៀបទៅនិងការទទួល សេវាផ្សេងៗទៀតក្នុងមូលដ្ឋាន។ ជាងនេះទៅទៀត មន្ត្រីបានលើកឡើងថា ចំពោះបញ្ហាអត្រានុកូលដ្ឋាននេះ មន្ត្រីមានការយល់ដឹងច្រើនពីបញ្ហាអត្រានុកូលដ្ឋាននេះ ពីព្រោះមានការបណ្តុះបណ្តាលជាញឹកញាប់តាមរយៈការអញ្ជើញឲ្យចូលរួមពីសំណាក់មន្ត្រីអង្គភាពមូលដ្ឋាន និងអង្គការ PLANE។ ម្យ៉ាងវិញទៀតមានការធ្វើយុទ្ធនាការអត្រានុកូលដ្ឋាននៅក្នុងឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ និងអង្គការ PLANE គឺចុះធ្វើសំបុត្រអត្រានុកូលដ្ឋាននេះដល់ប្រជាពលរដ្ឋគ្រប់ៗគ្នាដល់លំនៅឋានតែម្តង និងមិនមានការបង់សេវានោះទេ។ ជាងនេះទៅទៀត គឺរាល់ការធ្វើសំបុត្រអត្រានុកូលដ្ឋាននេះ គឺមន្ត្រីធ្វើឡើងដោយផ្អែកទៅតាមលិខិតគតិយុត្តិជាចម្បងដូចជា ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីអំពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីអំពីអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានជាច្រើនទៀតដែលពាក់ព័ន្ធ មិនមានការពឹងផ្អែកទៅលើទំនៀមទំលាប់នោះទេ។ លើសពីនេះទៅទៀត ចំពោះរយៈពេលនៃការផ្តល់សេវានេះ គឺមន្ត្រីមានការផ្តល់ជូនយ៉ាងទាន់ពេលវេលា និងតាមតម្លៃដែលសាលារាជធានីបានធ្វើសេចក្តីណែនាំ និងមានការធ្វើវិក័យបត្រ័ជូនផងដែរ រៀរលែងតែមានការខ្វះខាតសៀវភៅបញ្ជី ដែលក្រសួងមហាផ្ទៃផ្តល់ជូនដល់សាលាសង្កាត់តែប៉ុណ្ណោះ។ ក្នុងនោះដែរ បើទោះបី មន្ត្រីមានការអះអាង ពីអត្ថប្រយោជន៍ជាច្រើនទាក់ទងទៅនិង យុទ្ធនាការរវាងក្រសួងមហាផ្ទៃ និង អង្គការPLANE ក៏ប្រជាពលរដ្ឋមួយចំនួនតូចនៅតែគ្មានសំបុត្រអត្រានុកូលដ្ឋានដដែល គឺមិនបានគ្រប់ៗគ្នានោះទេ បើយោងទៅលើការសាកសួរ ប្រជាពលរដ្ឋផ្ទាល់។ នេះក៏សបញ្ជាក់ពីភាពខ្វះចន្លោះ បន្តិចបន្តួចនៃការអនុវត្តន៍ការងារមន្ត្រីមួយចំនួនដែរ ទើបបណ្តាលឲ្យមានបញ្ហាបែបនេះកើតឡើង។ ម្យ៉ាងវិញទៀត ដោយសារតែមន្ត្រីអនុវត្តការងារអត្រានុកូលដ្ឋាននេះដោយមានការពឹងផ្អែក ទៅលើតែលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានទាក់ទងទៅនិងលក្ខខណ្ឌ និងឯកសារដើម្បីទទួលបាននូវលិខិតអត្រានុកូលដ្ឋាននេះ ទើបធ្វើឲ្យមន្ត្រីមានការទាមទារនូវឯកសារច្បាប់គ្រប់គ្រាន់ ទើបមន្ត្រីសម្រេចធ្វើសំបុត្រអត្រានុកូលដ្ឋាននេះជូន ប៉ុន្តែ

ប្រជាពលរដ្ឋមួយចំនួនមិនបានយល់បែបនេះទេ បែរជាមានការរអ៊ូរទាំយល់ថារដ្ឋបាលមានលក្ខណៈស្មុគស្មាញទៅវិញ នេះហើយជាបញ្ហាប្រឈមរបស់មន្ត្រី និងប្រជាពលរដ្ឋ។

ដូចនេះ ក្នុងការងារអត្រានុកូលដ្ឋាន ក្នុងខណ្ឌច្បារអំពៅ គឺមានការសហការល្អ និងមិនមានភាពបញ្ហាអវិជ្ជមានជាធ្ងន់ធ្ងរដែលមិនអាចស្វែងរកដំណោះស្រាយនោះទេ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋក៏បានបង្ហាញពីបញ្ហាវិជ្ជមានជាច្រើនទាក់ទងនិងការងារអត្រានុកូលដ្ឋាន ប៉ុន្តែទន្ទឹមនឹងនេះ បញ្ហាអវិជ្ជមានប្រាកដជាមាន បន្តិចបន្តួចក្នុងការងារនេះដោយប្រជាពលរដ្ឋមួយចំនួនតូចមិនបានមកធ្វើសំបុត្រអត្រានុកូលដ្ឋានដោយខ្លួនផ្ទាល់បែរជាពឹងទៅមន្ត្រីសង្កាត់ខ្លះរត់រកខាងក្រៅហើយឲ្យកំរ៉ៃសេវាលើសពីការកំណត់ក្នុងប្រកាសអន្តរក្រសួង និងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលកត្តានេះហើយទើបបានជាមានអំពើពុករលួយកើតឡើងក្នុងមូលដ្ឋាន។ នេះជាបញ្ហាអវិជ្ជមានដែលបង្កឡើងដោយមន្ត្រី និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន[63]។

### ៣.១.២. សេវាសុខាភិបាលក្នុងមូលដ្ឋាន

សាលាខណ្ឌច្បារអំពៅ បានផ្តោតការយកចិត្តទុកដាក់ទៅលើសេវាសុខាភិបាលខ្លាំង ពីព្រោះដើម្បីចូលរួមចំណែកក្នុងការថែរក្សាសុខុមាលភាពប្រជាពលរដ្ឋ និងដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។ សាលាខណ្ឌច្បារអំពៅបានបង្កើតឲ្យមាននូវមណ្ឌលសុខភាពគ្រប់សង្កាត់ទាំងអស់ក្នុងមូលដ្ឋាន។ លើសពីនេះទៅទៀត សាលាខណ្ឌច្បារអំពៅបានសហការជាមួយនិងអង្គការURC (University Research Co) បង្កើតឲ្យមានប័ណ្ណមូលនិធិសមធមិជូនគ្រួសារប្រជាពលរដ្ឋក្នុងមូលដ្ឋានផ្ទាល់។ ដោយក្នុងប័ណ្ណនេះ គឺមានការផ្តល់ជូនតែគ្រួសារនៃប្រជាពលរដ្ឋក្រីក្រក្នុងខណ្ឌច្បារអំពៅតែប៉ុណ្ណោះ ហើយម្យ៉ាងវិញទៀតការទទួលបាននូវប័ណ្ណនេះមានន័យថា គ្រួសារនៃប្រជាពលរដ្ឋ ក្រីក្រទាំងមូល មានអ្នកបង់សេវាជំនួសតែម្តង បូករួមទាំងថ្លៃបាយទឹករាល់ពេលសម្រាកពេទ្យ ការផ្តល់ សេវាជូនអ្នកកំដរ និងសេវាសោហ៊ុយធ្វើដំណើរផងដែរ ហើយប័ណ្ណមូលនិធិសមធមិនេះ មិនមានការដកហូតវិញក្នុងករណីគ្រួសារនោះមានជីវភាពប្រសើរឡើងជាងមុនក៏ដោយ ជាងនេះទៅទៀតការ ពិនិត្យ និងព្យាបាលសុខភាពតាមរយៈប័ណ្ណសមធមិនេះ គឺបើសិនជាក្នុងមណ្ឌលសុខភាពមិនមាន លទ្ធភាពព្យាបាល មណ្ឌលសុខភាពនោះនឹងបញ្ជូនទៅព្យាបាលនៅមន្ត្រីពេទ្យ រុស្សី។ ហេតុនេះហើយទើបប្រជាពលរដ្ឋក្នុងមូលដ្ឋាន មានភាពងាយស្រួលក្នុងការថែរក្សាសុខភាពរបស់ខ្លួនផ្ទាល់ ទោះបីប្រជាពលរដ្ឋដែលគ្មានប្រាក់ដើម្បីព្យាបាលជម្ងឺក៏ដោយ។ ទោះជាបែបនេះក្តី ដោយយោងទៅលើការសាកសួរពីសំណាក់មន្ត្រី និងប្រជាពលរដ្ឋក្នុងខណ្ឌទាក់ទងនិងបញ្ហាសុខាភិបាលនេះ យើងទទួលបានថា ទោះជាមានការផ្តល់ជូនបែបនេះក្តី ប៉ុន្តែការកំណត់ចំនួនគ្រួសារក្រីក្រនៅក្នុងខណ្ឌ សង្កាត់ដែលត្រូវបានទទួល

[63] កែវ រស្មី ″ អភិបាលកិច្ចល្អខណ្ឌមានជ័យ″ ឆ្នាំ២០១៤ ទំព័រទី៤៣

ប័ណ្ណនេះពីសាលាខណ្ឌច្បារអំពៅ ដូចនេះហើយទើបបណ្ដាលឲ្យប័ណ្ណមូលនិធិសមធម៌នេះមិនបាន ផ្ដល់ជូនបានគ្រប់ចំនួននៃគ្រួសារក្រីក្រក្នុងសហគមន៍ទេ។

ជាងនេះទៅទៀតក៏មានផលអវិជ្ជមានចំពោះ បញ្ហាឥរិយាបទ របស់គ្រូពេទ្យចំពោះអ្នកជម្ងឺផង ដែរគឺមានការរើសអើងមួយចំនួនទៅលើអ្នកជម្ងឺដែលមានសភាពក្រីក្រខ្លាំង មានសំលៀកបំពាក់មិនសម រម្យនោះ ទោះជាក្រុមគ្រូពេទ្យនោះបានទទួលការណែនាំក្នុងពេលប្រជុំទាក់ទងនិងបញ្ហានេះ ក៏ ដោយ។ ដូចនេះដែរ ប្រជាពលរដ្ឋក៏ដូចគ្នា មាននប្រជាពលរដ្ឋមួយចំនួនបានគិតថា អាងតែខ្លួនមាន ប័ណ្ណបាន ទាមទា និងបញ្ជាឲ្យពេទ្យផ្ដល់នូវថ្នាំដែលខុសពីអាការៈនៃអ្នកជម្ងឺ។ ដូចជាមានករណីជាក់ស្ដែងមួយកើត ឡើងក្នុងមណ្ឌលសុខភាពខណ្ឌច្បារអំពៅ ដោយប្រជាពលរដ្ឋមកទទួលសេវានេះ មាន ជម្ងឺផ្ដាសាយ លក្ខណៈស្រាល ប៉ុន្ដែបែរជាទាមទារឲ្យគ្រូពេទ្យដាក់នូវសារ៉ូមជូន ប៉ុន្ដែនៅពេលដែល គ្រូពេទ្យ លើក ឡើងថាលេបតែថ្នាំតាមវិជ្ជបញ្ជា គឺវានឹងជាសះស្បើយ បែរជាប្រជាពលរដ្ឋយល់ថាមិនមានការថែទាំបាន ល្អទៅវិញ។ ហេតុដូច្នេះហើយ ទើបមានការនិយាយតៗគ្នាពីបញ្ហានេះធ្វើឲ្យប្រជាពលរដ្ឋក្រីក្រដែលមាន ប័ណ្ណនេះ មិនបានមកទទួលសេវាសុខា ភិបាលតាមរយៈប័ណ្ណនេះទេ ដោយទុកប័ណ្ណនេះចោល។ ដូច នេះយើងយល់ថា សេវាថែទាំសុខភាព នៅមិនទាន់មានភាពរលូននៅឡើយទេ ដែលកត្តាទាំងអស់នេះ កើតឡើងពីមន្រ្ដី និងប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ និងទាមទារឲ្យមានការពន្យល់ណែនាំបន្ថែមពីសំណាក់ អាជ្ញាធរដែលពាក់ព័ន្ធទៅលើមន្រ្ដីសុខាភិបាលមូលដ្ឋាន និងប្រជាពលរដ្ឋបន្ថែមទៀត។

**៣.១.៣. សេវាអប់រំ**

ការអប់រំ ក៏ជាវិស័យអាទិភាពមួយក្នុងចំនោមចង្កោម នៃសេវាសាធារណៈហើយក៏ជាចំណុច ចម្បងក្នុងការអភិវឌ្ឍន៍នៃគោលការណ៍អភិបាលកិច្ចល្អផងដែរ។ ក្នុងនោះដែរសាលាខណ្ឌច្បារអំពៅបាន យកចិត្តទុកដាក់ជាទីបំផុត ក្នុងការបង្កើន ជម្រុញ និងបណ្ដុះនូវធនធានមនុស្សនេះ។

តាមរយៈការយកចិត្តទុកដាក់នេះ សាលាខណ្ឌច្បារអំពៅបានបង្កើតគ្រឹះស្ថានអប់រំជាច្រើន កន្លែង និងមានការបង្កើតនូវកម្មវិធីមូលដ្ឋានផ្សេងៗក្នុងការផ្សព្វផ្សាយក្នុងកិច្ចនៃវិស័យអប់រំ។ នៅទូទាំង ខណ្ឌច្បារអំពៅ មានសាលាមត្តេយ្យ ៥សាលាស្មើនឹង៣ថ្នាក់ ក្នុងនោះមានកុមារអាយុពី៣ទៅ៥ឆ្នាំបាន ចូលរៀន ២,៣១៧នាក់ ស្រី១១៤៣នាក់ បុគ្គលិក២៧នាក់ ជាមនុស្សស្រី។ សាលាបឋមសិក្សា២០ ស្មើ នឹង៣០១បន្ទប់ មានចំនួនសិស្សសរុប ១៣,២៩៨នាក់ ស្រី៦,៣៩២នាក់ សិស្សចូលរៀនថ្មី ៧៨៧នាក់ ស្រី ៣៩៩នាក់ បុគ្គលសរុប ៣៨២នាក់ ស្រី២៧០នាក់។ សាលាអនុវិទ្យាល័យ៤សាលា ស្មើនឹង៣០ បន្ទប់ ចំនួនសិស្សសរុប១,២០២នាក់ ស្រី៥៦៣នាក់ បុគ្គលិក១២២នាក់ ស្រី៥៩នាក់ លទ្ធផលជាប់១,១២១ នាក់ គិតជាភាគរយ ៩៣,២៦%។ និងសាលាវិទ្យាល័យមាន៧សាលា ស្មើនឹង១៧១ថ្នាក់ សិស្សសរុប ៧,០៧៦នាក់ ស្រី៣៥២១នាក់ បុគ្គលិកសរុប៥១១នាក់ ស្រី២២៥នាក់។ ក្នុងនោះផងដែរ ការងារអប់រំយុវ

ជន និងកីឡា ក៏បានបង្កើតថ្នាក់មួយចំនួនទៀត គឺថ្នាក់អក្ខរកម្ម ដែលស្ថិតនៅក្នុងសង្កាត់ ព្រែកប្រា និង សង្កាត់ព្រែកថ្មី ព្រមទាំងត្រៀមបើកថ្នាក់អក្ខរកម្មចំនួន០៤ ថ្នាក់ទៀត។ ថ្នាក់អប់រំបញ្ចូលគ្នា គ ថ្លង់ ស្ថិតនៅក្នុងសាលាបឋមសិក្សាឬស្សីស្រស់ មានថ្នាក់បញ្ចូលគ្នារវាងសិស្ស គ ថ្លង់ និងសិស្ស ធម្មតា ចំនួន០២កម្រិតថ្នាក់ គឺថ្នាក់ទី៥ និងទី៦រួមមាន: ថ្នាក់ទី៥មានសិស្សសរុប១០នាក់ ស្រី០៤នាក់។ ថ្នាក់ទី ៦មានសិស្សសរុប ០៧នាក់ ស្រី០៥នាក់[64]។

ក្រុមប្រឹក្សាខណ្ឌបានយកចិត្តទុកដាក់អនុវត្តន៍ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើ ការអប់រំមូលដ្ឋាន (ពីថ្នាក់ទី១ ដល់ថ្នាក់ទី៩) និង ជម្រុញលើកទឹកចិត្តគ្រូបង្រៀន និង សិស្សពូកែ ផ្តល់ សម្ភារៈ បរិក្ខា ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដើម្បីកាត់បន្ថយការបោះបង់ការសិក្សារបស់ សិស្សានុសិស្ស។

## ៣.២. ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

ការចូលរួមនៅក្នុងបរិបទនៃ អភិបាលកិច្ចល្អ គឺសំដៅទៅលើការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ទាំងប្រុសទាំងស្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចនោះ។ ដូចគ្នានេះដែរបើយោងទៅតាមការសាកសួរ ពីសំណាក់មន្ត្រីមូលដ្ឋាន ក្នុងខណ្ឌច្បារអំពៅយើងឃើញថាមន្ត្រីសង្កាត់មានការខ្វាយខ្វល់និងជម្រុញឲ្យ សកម្មភាពចូលរួមកាន់តែមានភាពល្អប្រសើរឡើងតាមរយៈការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីសំណាក់ មន្ត្រី ក្នុងមូលដ្ឋាន អំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួមរបស់ប្រជាពលរដ្ឋខិតខំផ្សព្វផ្សាយ ព័ត៌មានស្តីពីកិច្ចប្រជុំ និងព័ត៌មានផ្សេងៗឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងបានកំណត់ពេល វេលា និងទីកន្លែងប្រជុំយ៉ាងសមស្រប។

ជាងនេះទៅទៀត មន្ត្រីឃុំ សង្កាត់ តែងតែខិតខំស្វែងរកនូវឱកាសជាច្រើនដើម្បីឲ្យប្រជាពលរដ្ឋ បានចូលរួមក្នុងមូលដ្ឋាន និងបានប្រើប្រាស់នូវភាពជាម្ចាស់នៃមូលដ្ឋានរបស់ខ្លួនយ៉ាងទូលំទូលាយ បើក ចំហរ និងគ្មានការគំរាមគំហែង។ កម្មវិធីដែលតែងតែមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងមូល ដ្ឋានមានដូចជា៖ ការប្រជុំនៅថ្នាក់ភូមិ នៃដំណើរការផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ការសិក្សាផលប៉ះពាល់បរិស្ថាន ក្នុងការធ្វើការអភិវឌ្ឍន៍ ការតាមដានត្រួតពិនិត្យលើការ អនុវត្ត ន៍កិច្ចសន្យាឃុំសង្កាត់ជាមួយក្រុមហ៊ុនទទួលធ្វើគម្រោង ការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រង គម្រោង ការផ្តល់ព័ត៌មាននានាជុំវិញការអនុវត្តន៍គម្រោង និងវេទិកាសាធារណៈ។ រាល់គម្រោងនេះ សុទ្ធតែមានការចូលរួមសហការពីសំណាក់ប្រជាពលរដ្ឋ។ ប៉ុន្តែក្នុងការចូលរួមនេះដែរ គឺមានតែការចូល រួមក្នុងវេទិការសាធារណៈតែប៉ុណ្ណោះ ដែលប្រជាពលរដ្ឋបានចូលរួមបានច្រើនជាងគេ ដោយសារតែ ប្រជាពលរដ្ឋបានយល់យ៉ាងច្បាស់ពីផលប្រយោជន៍ទាក់ទងទៅនិងវេទិការសាធារណៈនេះ ម្យ៉ាងវិញ

[64] របាយការណ៍ ស្តីពី លទ្ធផលនៃការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌច្បារអំពៅប្រចាំឆ្នាំ២០១៨ ទំព័រទី១៥៤។

ទៀតប្រជាពលរដ្ឋមានការចង់ដឹង ពីការប្រែប្រួលពីសភាពការណ៍មូលដ្ឋាន និងអត្ថប្រយោជន៍នៃការជួបផ្ទាល់នៃថ្នាក់ដឹងនាំ។ ហេតុដូច្នេះហើយទើប មានការចូលរួមពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើននៅក្នុងការបញ្ចេញមតិផ្សេងៗនៅក្នុង វេទិការសាធារណៈដែល មន្ត្រីសង្កាត់តែងតែអនុវត្តន៍ តាមរយៈសេចក្ដីណែនាំរបស់សាលាក្រុងក្នុងការបើកវេទិការសាធារណៈយ៉ាងតិចមួយដងក្នុងមួយខែ ប៉ុន្តែក្នុងសង្កាត់ខ្លះដោយសារមន្ត្រីបានដឹងពីបញ្ហាអវិជ្ជមានក្នុងមូលដ្ឋានច្រើនទើបមានការបើក វេទិកាសាធារណៈនេះក្នុងមួយខែ ពីរ ទៅបីដង និងមានការសហការគ្នាយ៉ាងស្អិតរមួតពីសំណាក់ប្រជាពលរដ្ឋតាមរយៈការផ្ដល់ព័ត៌មាន និងបញ្ហាអវិជ្ជមានទាន់ពេលវេលា។ ទោះបីជាបែបនេះក្ដី បញ្ហាមួយចំនួនក៏នៅតែកើតមានចំពោះ ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ នេះបើយោងតាមការសាកសួរផ្ទាល់ពីសំណាក់មន្ត្រីសាលាសង្កាត់គឺយើងឃើញថា មានប្រជាពលរដ្ឋភាគច្រើនហ៊ានបញ្ចេញមតិ គ្រប់បញ្ហាទាក់ទង និងផលវិបាក ទុក្ខកង្វល់ ឬការមិនពេញចិត្តមួយចំនួនក្នុងមូលដ្ឋាន ប៉ុន្តែចំពោះបញ្ហាគ្រឿងញៀន និងល្បែងខុសច្បាប់ដែលប្រជាពលរដ្ឋបានដឹងគឺ ប្រជាពលរដ្ឋនៅតែមានភាពភ័យខ្លាចពីសុវត្ថិភាពក្នុងការបញ្ចេញមតិក្នុងវេទិការសាធារណៈ ផ្ទុយទៅវិញប្រជាពលរដ្ឋតែងតែផ្ដល់ព័ត៌មានដល់សង្កាត់តាមរយៈប្រអប់សំបុត្រ ឬតាមទូរស័ព្ទទៅមន្ត្រីសង្កាត់ ជាហេតុធ្វើឲ្យពេលខ្លះខាងសង្កាត់មានការយឺតពេល បន្តិចបន្តួចក្នុងការដោះស្រាយនៅបញ្ហានោះ។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋមួយចំនួនក្នុងមូលដ្ឋាន ដែលមានភាគតិចមិនបានចូលរួមក្នុងការសម្រេចចិត្តផ្សេងៗដែលអាជ្ញាធរបានផ្ដល់ឲ្យនោះ ដោយសារតែប្រជាពលរដ្ឋមួយចំនួននោះជីវភាពនៅមានកម្រិត ទើបមានការរវល់នឹង ស្វះស្វែងតែចំពោះបញ្ហាជីវភាព និងមិនខ្វាយខ្វល់ពីភាពជាម្ចាស់មូលដ្ឋានរបស់ខ្លួន[65]។

## ៣.៣. ការទទួលខុសត្រូវ និងគណនេយ្យភាពរបស់ខណ្ឌ

ចំពោះការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងមូលដ្ឋានពិតជាមានសារៈសំខាន់ណាស់ក្នុងការ ជម្រុញឲ្យមាន អភិបាលកិច្ចល្អក្នុងមូលដ្ឋាន។ ក្នុងនេះដែរ យើងបានលើកយកមកនូវការទទួលខុសត្រូវ និងគណនេយ្យភាពរបស់តំណាងរបស់ប្រជាពលរដ្ឋឃុំ សង្កាត់ ពីព្រោះតំណាងក្នុងមូលដ្ឋាននេះបានកើតឡើងដោយការបោះឆ្នោត ដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដែលតំណាងនោះរួមមាន៖ ក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មាធិការកសាងផែនការ និងថវិកាគណៈកម្មាធិការលទ្ធកម្ម គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ក្រុមប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង គណៈកម្មាធិការធនធានធម្មជាតិ និងអង្គការសហគមន៍មូលដ្ឋាន។ អ្នកតំណាងនេះ គឺជាអ្នកតំណាងរបស់ប្រជាពលរដ្ឋផ្ទាល់ ដោយធ្វើការសម្រេចចិត្តក្នុងនាមប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ ដោយយោងទៅតាមការសាកសួរ ពីសំណាក់មន្ត្រីមូលដ្ឋានបានបង្ហាញថា មន្ត្រីក្នុងមូលដ្ឋានតែងតែទទួលខុសត្រូវចំពោះ

[65] សៀវភៅ " អភិបាលកិច្ចល្អខណ្ឌមានជ័យ" ឆ្នាំ២០១៤ ទំព័រទី៤៨

ទង្វើរបស់ខ្លួនជូនប្រជាពលរដ្ឋ តាមរយៈការរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុ ដែលខ្លួនបានធ្វើការសម្រេចចិត្ត និងអនុវត្តន៍។ មូលហេតុដែលមន្ត្រីហ៊ាងអះអាងថាមានការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងមូលដ្ឋាននោះពីព្រោះ ក្នុងការប្រជុំកំណត់ទីតាំងគម្រោង ការអនុម័តនូវគម្រោង គឺមានការប្រជុំពីសំណាក់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និងក្រុមប្រឹក្សាដែលជាតំណាងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ប៉ុន្តែផ្ទុយទៅវិញ នៅក្នុងការកំណត់ទីតាំងគម្រោង គឺប្រជាពលរដ្ឋមួយចំនួនតូចក៏មានការមិនពេញចិត្តដែរ។ ដូចនេះ យើងអាចបង្ហាញថា ការទទួលខុសត្រូវក្នុងថ្នាក់ឃុំ សង្កាត់ពិតជាមានសារៈសំខាន់ ប៉ុន្តែគ្រាន់តែមានការខ្វះចន្លោះមួយចំនួនតែប៉ុណ្ណោះ[66]។

## ៣.៤. សមត្ថភាពមន្ត្រីក្នុងការជម្រុញអភិបាលកិច្ចល្អ

ជាការពិតណាស់ ក្នុងការអនុវត្តន៍នៃគោលការណ៍អភិបាលកិច្ចល្អនេះមានភាពល្អប្រសើរណាស់ក្នុងសាលាខណ្ឌច្បារអំពៅ ប៉ុន្តែក្នុងនោះដែរក៏មានកង្វះខាតមួយផ្នែកតូចដែលទាក់ទងទៅនិងមន្ត្រី និងប្រជាពលរដ្ឋ។

ចំពោះមន្ត្រីក្នុងសង្កាត់ ក៏ដូចជាមន្ត្រីក្នុងសាលាខណ្ឌច្បារអំពៅសុទ្ធតែធ្លាប់បានអញ្ជើញឲ្យចូលរួមក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងវគ្គខ្លីៗ ស្តីពីអភិបាលកិច្ចល្អ។ ការចូលរួមនេះដែរ គឺតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ដោយអង្គការទាំងនេះតែងតែគាំទ្រការបណ្តុះបណ្តាល និងកសាងសមត្ថភាពជូនមន្ត្រី។ លើសពីនេះទៅទៀត ក៏មាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន របស់សាលារាជធានីភ្នំពេញដែលជាសេនាធិកាចំពោះការងារទាំងអស់ទាក់ទងវិមជ្ឈការនិងការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់។ នាយកដ្ឋាននេះទទួលការពិនិត្យតាមដាន ការវាយតម្លៃ រាយការណ៍អំពីសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សា ឃុំសង្កាត់ និងស្មៀន។ នាយកដ្ឋាននេះត្រូវបានធានាថាវិធានការត្រឹមត្រូវសម្រាប់ ការបណ្តុះបណ្តាល និងកសាងសមត្ថភាព ដែលរួមមានការអប់រំ សាធារណៈជនផងដែរ។

ការអភិវឌ្ឍន៍សមត្ថភាព៖

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
| ១ | វគ្គសិក្សា | ៩៥ | ១០០ | ៩០ | ៦៧ | ៨៣ | ៤៣៥ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៩៤៣ | ១,១០៩ | ១,០២៥ | ៩២៥ | ១,៣០១ | ៥,៣០២ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៥៩៧ | ៧១១ | ៧៦០ | ៧០៦ | ៧៥៥ | ៣,៥១១ |

*ប្រភព៖ របាយការណ៍របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២*

[66] របាយការណ៍ខណ្ឌច្បារអំពៅ ឆ្នាំ២០១៨

ជាការពិតណាស់ សមិទ្ធផលដែលបានធ្វើកន្លងមកនេះខណ្ឌច្បារអំពៅ បានធ្វើការកសាងសមត្ថភាពទៅលើមន្ត្រី យ៉ាងយកចិត្តទុកដាក់ និងមានការសហការពីមន្ត្រីជាច្រើន។ បើយើងក្រឡេកទៅលើតារាងសមិទ្ធផលទាក់ទងនិងសមត្ថភាពមន្ត្រីក្នុងការចូលរួមក្នុងសិក្ខាសាលាផ្សេងៗ គឺយើងឃើញថា វគ្គសិក្សាសម្រាប់មន្ត្រីមានច្រើនក្នុងមួយឆ្នាំៗហើយសិក្ខាកាមជាស្ត្រីក៏មានការកើនឡើងជាលំដាប់។

ជាក់ស្តែងក្នុងការសាកសួរផ្ទាល់ពីសំណាក់មន្ត្រីក្នុងខណ្ឌ យើងឃើញថា មន្ត្រីដែលទទួលការបណ្តុះបណ្តាលនេះ គឺបានទទួលនូវការយល់ដឹងយ៉ាងច្រើន ទាក់ទងនិងគោលការណ៍អភិបាលកិច្ចល្អនេះ ប៉ុន្តែទន្ទឹមនិងនេះក៏មានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹង ការកសាងសមត្ថភាពមន្ត្រីគឺ ចំពោះការអញ្ជើញពីសំណាក់ ស្ថាប័នរដ្ឋទាក់ទងនិងសិក្ខាសាលាផ្សេងៗ និងវគ្គខ្លីៗគឺមិនមានការចូលរួមបានគ្រប់មន្ត្រីនោះទេ ភាគច្រើនអ្នកដែលចូលរួមទទួលនូវចំនេះដឹងទាក់ទងនឹងអភិបាលកិច្ចល្អនេះគឺមានតែ៖ ចៅសង្កាត់ ចៅសង្កាត់ទី១ និងទី២ ក្រុមប្រឹក្សា និងស្មៀន។ ផ្ទុយទៅវិញមេភូមិ និងមន្ត្រីសង្កាត់ ផ្សេងៗមិនបានចូលរួមនោះទេ ដោយឡែកមានតែអង្គការមិនមែនរដ្ឋាភិបាលទេ ដែលមានអញ្ជើញ មេភូមិ និងមេឃុំឲ្យចូលរួម។ ហេតុដូច្នេះហើយទើបយើងអាចនិយាយបានថា ការយល់ដឹងនូវគោលការណ៍ នៃអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាននេះពិតជានៅមានកម្រិតនៅឡើយ។ លើសពីនេះទៅទៀតបើយើងក្រឡេកមើលទៅលើមូលដ្ឋានគតិយុត្តិក្នុងការពង្រឹងអភិបាលកិច្ចល្អ គឺដោយយោងតាមការសាកសួរផ្ទាល់ពីមន្ត្រីសង្កាត់មានការផ្អែកទៅលើសៀវភៅណែនាំរបស់សាលារាជធានី និងសេចក្តីណែនាំផ្សេងៗដូចជា សេចក្តីណែនាំរបស់សាលាក្រុងក្នុងការបង្កើតវេទិកាសាធារណៈយ៉ាងតិច មួយដងក្នុងមួយខែ និងសេចក្តីណែនាំស្តីពីការប្រមូលទុនចូលរួមរបស់មូលដ្ឋាននៃគម្រោងអភិវឌ្ឍន៍ មូលដ្ឋាន មិនមានការធ្វើសេចក្តីសម្រេចណាមួយដែលផ្អែកលើគោលការណ៍ ទំនៀមទំលាប់នោះទេ គឺយកច្បាប់ជាធំ[67]។

**៣.៥. បញ្ហាប្រឈម**

ទោះបីជាខណ្ឌមានឱកាសក្នុងការអភិវឌ្ឍន៍មូលដ្ឋានក្នុងខណ្ឌ សង្កាត់របស់ខ្លួនទាំងអស់ក៏ដោយ ក៏យើងសង្កេតឃើញថា នៅតែមានចន្លោះខ្វះខាត ដែលខណ្ឌពុំទាន់បានធ្វើការឆ្លើយតបទៅនឹងបញ្ហានានាមួយចំនួនដែលចោទមានឡើង។ ហើយបញ្ហាដែលចោទមានឡើងនោះ ខណ្ឌកំពុងតែ ស្វះស្វែងរកដំណោះស្រាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ដែលបញ្ហាទាំងអស់នោះរួមមាន៖

- សមត្ថភាពរបស់មន្ត្រីនៅមានកម្រិត ពីព្រោះទាក់ទងនិងការបណ្តុះបណ្តាល និងកម្រិតវប្បធម៌ម្យ៉ាងវិញទៀតមានបណ្តុះបណ្តាលចំពោះមន្ត្រី ក៏មិនមានភាពប្រសើរឡើយ គឺមន្ត្រីមិនបានទទួលការបណ្តុះបណ្តាលបណ្តាញដល់គ្រប់មន្ត្រី ក្នុងស្ថាប័ននោះទេ

[67] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់ខណ្ឌច្បារអំពៅប្រចាំឆ្នាំ២០១៨

- ការយកចិត្តទុកដាក់របស់មន្ត្រី ក្នុងការងារនៅមានកម្រិត និងខ្វះឆន្ទៈក្នុងការងារពីព្រោះវាមានភាពទាក់ទងទៅនិងកម្រិតជីវភាពរបស់មន្ត្រី ដោយមន្ត្រីមួយចំនួននៅមានភាពខ្វះខាតក្នុង ជីវភាព។
- ការចូលរួមរបស់ប្រជាពលរដ្ឋក៏មិនមានភាពសហការបានគ្រប់នូវកម្មវិធីមូលដ្ឋាននោះដែរ គឺមានការចូលរួម ភាគច្រើនចំពោះតែ កម្មវេទិការសាធារណៈតែប៉ុណ្ណោះ។ វាក៏សបញ្ជាក់ពីបញ្ហាយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ទាក់ទងទៅ និងការចូលរួម និងភាពជាម្ចាស់នៃមូលដ្ឋាន
- ប្រជាពលរដ្ឋមួយចំនួន ពុំបានរក្សាទុកនូវឯកសារអត្រានុកូលដ្ឋានផ្ទាល់ខ្លួនឲ្យបានល្អ បណ្តាលឲ្យបាត់ច្បាប់ដើម និងរហែក ធ្វើឲ្យមន្ត្រីទទួលបន្ទុកផ្នែកអត្រានុកូលដ្ឋាន ពីបាកក្នុងការស្រាវជ្រាវរកសៀវភៅគល់បញ្ជីជូនពួកគាត់។ សេវាសាធារណៈក្នុងមូលដ្ឋានក៏បានបង្ហាញពី បញ្ហាអវិជ្ជមានមួយចំនួនផងដែរ ទាក់ទងនិងសេវាមធ្យោបាយ និងពេលវេលា។
- ប្រជាពលរដ្ឋមួយចំនួនមិនទាន់យល់ច្បាស់អំពីការសុំច្បាប់សាងសងផ្ទះនាំឲ្យមានការសាងសង់សំណង់ខុសច្បាប់ និងសាងសង់លើដីសាធារណៈរបស់រដ្ឋ ជាពិសេសកើតឡើងនៅសង្កាត់វាលស្បូវ, សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី ទោះបីជាក្រុមការងារបានចុះណែនាំ និងធ្វើកំណត់ហេតុផ្អាក់ការសាងសង់ក៏ដោយ។
- ករណីទំនាស់ដីធ្លីកើតឡើងច្រើនដោយសារមូលហេតុមិនទាន់បានចុះបញ្ជីដីធ្លី ជាលក្ខណៈប្រព័ន្ធឲ្យបានគ្រប់សង្កាត់នៅឡើយ។
- ខ្វះការអប់រំផ្សព្វផ្សាយ និងការជម្រុញឲ្យប្រើប្រាស់សេវានៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ព្រមទាំងជម្រុញឲ្យសហគមន៍ មកទទួលសេវានៅមូលដ្ឋានសុខាភិបាលឲ្យបានច្រើន។
- ការផ្តល់សេវាមូលដ្ឋាន(ផ្តល់ថ្នាំបង្ការដល់ភូមិងាយរងគ្រោះ) មានឧបសគ្គមួយចំនួនដូចជា ការផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋមួយចំនួនចេញទៅប្រកបមុខរបរឆ្ងាយពីផ្ទះដោយយកកូនតូចទៅជាមួយ។
- នៅតាមមូលដ្ឋានមួយចំនួន នៅតែកើតមានអំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ។

- ប្រជាពលរដ្ឋខ្លះ ពុំសូវយកចិត្តទុកដាក់ចូលរួមក្នុងការអប់រំផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះថ្នាក់ ច្បាប់ប្រឆាំងការជួញដូរ និងការរំលោភសេពសន្ថវៈ ដោយអ្នកចូលរួមភាគច្រើនជាស្ត្រី ដែលជាជនរងគ្រោះ[68]។

## ៣.៦.ទិសដៅសកម្មភាពនាពេលអនាគត

សាលាខណ្ឌច្បារអំពៅបានរៀបចំទិសដៅការងារឆ្នាំបន្ទាប់ដើម្បីផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋដូចជា៖រៀបចំកិច្ចប្រជុំសាមញ្ញចំនួន១២លើក និងវិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២ រៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅ រៀបចំប្រជុំគណៈកម្មាធិការរៀបចំ ដែនដី និងនគរូបនីយកម្មថ្នាក់ខណ្ឌ ចូលរួមក្នុងវេទិកាការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅ និងក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី២ បន្តពង្រឹងការអនុវត្តន៍តួនាទីភារកិច្ចរបស់មន្ត្រី បុគ្គលិក ការិយាល័យចំណុះ ជំនាញខណ្ឌ បន្តការដោះស្រាយសំណួរ សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋដែលលើកឡើងក្នុងវេទិការសាធារណៈរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខណ្ឌច្បារអំពៅអាណត្តិទី២ ចូលរួមក្នុងវេទិការសាធារណៈក្នុងសង្កាត់ទាំង០៨ រៀបចំវេទិកាសាធារណៈជាមួយមន្ត្រីចំនួន០២លើក រៀបចំយុទ្ធនាការផ្សព្វផ្សាយ ផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ ត្រួតពិនិត្យ និងពន្លឿនការផ្តល់សៀវភៅ(ក២) សៀវភៅ(ក៤) និង អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ ការបំបែកក្បាលដីនៅតាមសំណង់ផ្ទះល្វែង បុរី ជូន ប្រជាពលរដ្ឋ សហការរៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីពង្រឹងសមត្ថភាពជូនមន្ត្រី និងបុគ្គលិករដ្ឋបាលខណ្ឌសហការរៀបចំវេទិការសាធារណៈនៅតាមសង្កាត់ទាំង០៨ សហការជាមួយអាជ្ញាធរសង្កាត់-ភូមិ និងអ្នកពាក់ព័ន្ធជុំវិញការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយកចិត្តទុកដាក់ ក្នុងការថែរក្សា ឯកសារអត្រានុកូលដ្ឋានគ្រប់ប្រភេទផ្ទាល់ខ្លួនឲ្យបានគង់វង្ស ជម្រុញការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីនីតិវិធីនៃការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន ដោយមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដោះស្រាយវិវាទដីធ្លីនិងសំណង់ បន្តជម្រុញនិងត្រួតពិនិត្យ ការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យជំនាញទាំងអស់ ចុះទប់ស្កាត់រាល់សំណង់សាងសង់គ្មានច្បាប់ និងសំណង់សាងសង់លើដីសាធារណៈរបស់រដ្ឋ ត្រៀមចុះពិនិត្យ និងប្រជុំសម្របសម្រួលដោះស្រាយរាល់ពាក្យបណ្តឹងដីធ្លី និងសំណង់ដែលកើតមានក្នុងខណ្ឌច្បារអំពៅ រៀបចំកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំរំកិល ២០២០-២០២៤និងរៀបចំកសាងផែនការអភិវឌ្ឍន៍បីឆ្នាំរំកិល ២០២០-២០២២របស់

[68] របាយការណ៍ការស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌច្បារអំពៅប្រចាំឆ្នាំ២០១៨ ទំព័រទី១៨៧ដល់ ១៨៨

ខណ្ឌច្បារអំពៅ ជម្រុញឲ្យមន្ត្រី វិស័យជំនាញដែលប្រចាំការនៅការិយាល័យច្រកចេញចូលតែមួយសហការជាមួយអាជ្ញាធរសង្កាត់ទាំង០៨ ចុះផ្សព្វផ្សាយ និងជម្រុញឲ្យអាជីវកម្មសុំច្បាប់បើកអាជីវកម្មឲ្យមានប្រសិទ្ធិភាព ទប់ស្កាត់រាល់បទល្មើសលួច បន្លំ ទំនាស់វិវាទ និងបន្តរៀបចំសណ្តាប់ធ្នាប់ អប់រំផ្សព្វផ្សាយសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សុខភាពស្ត្រី និងកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរស្ត្រីនិងកុមារ ការការពារពលកម្មកុមារ[69]។

[69] របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌច្បារអំពៅប្រចាំឆ្នាំ២០១៨ ទំព័រទី១៩០ដល់១៩៦

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាទៅលើអភិបាលកិច្ចល្អនៅក្នុងមូលដ្ឋានរួចមក យើងសង្កេតឃើញថា អភិបាលកិច្ចគឺជា វិធីសាស្ត្រក្នុងការគ្រប់គ្រង និងដឹកនាំយ៉ាងល្អបំផុត។ ក្នុងនោះដែរ យើងទាមទារឲ្យតួអង្គនៃអភិបាលកិច្ចនោះព្យាយាមខិតខំពង្រឹង និងជម្រុញនូវគោលការណ៍អភិបាលកិច្ចល្អនេះឲ្យស្របទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាលដែលបានចាត់ទុកអភិបាលកិច្ចល្អ ជាយុទ្ធសាស្ត្រស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក្នុងកំណែទម្រង់រដ្ឋបាលស៊ីជម្រៅ និងជាយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ។ ហើយក្នុងនោះការអនុវត្តន៍នូវទ្រឹស្តីអភិបាលកិច្ចល្អនេះឲ្យមានប្រសិទ្ធិភាពក៏ទាមទារពីការខិតខំប្រឹងប្រែងនៃមន្ត្រីមួយចំនួនផងដែរ ដូចជាការលើកកម្ពស់នូវការដឹកនាំប្រកបដោយ តម្លាភាព ការឆ្លើយតប ការទទួលខុសត្រូវ គណនេយ្យភាព ការចាត់ចែងល្អ ប្រសិទ្ធិភាពខ្ពស់ ការព្រមព្រៀង ការឯកភាពគ្នា និងគិតគូរជាពិសេសនូវសេវាសាធារណៈជូនទៅប្រជាពលរដ្ឋគ្រប់រូបនៅក្នុងមូលដ្ឋាន ក៏ដូចជាសាធារណៈជនផ្សេងៗដែលពាក់ព័ន្ធ។

ឆ្លងកាត់តាមការអនុវត្តក្នុងរយៈពេលមួយអាណត្តិកន្លងមកនេះ ទោះបីជាសាលាខណ្ឌសម្រេចបានសមិទ្ធផលជាច្រើនក្តី ប៉ុន្តែយើងអាចវាយតម្លៃបានថា អភិបាលកិច្ចមូលដ្ឋានមានលក្ខណៈស្មុគស្មាញដែលទាមទារឲ្យមានការរៀបចំ និងការកែសម្រួលជាច្រើន និងត្រូវការពេលវេលានិងការសម្រេចបាននូវទិសដៅដែលបានដាក់ចេញ។

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់បន្តពង្រឹង និងពង្រីកការអនុវត្តន៍គោលនយោបាយ ដោយពិចារណាយ៉ាងល្អិតល្អន់លើការផ្ទេរអំណាចពីថ្នាក់លើមកថ្នាក់ក្រោមឲ្យបានឆាប់រហ័ស ហើយកំណត់ឲ្យបានកាន់តែច្បាស់លាស់នូវតួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ជាក់ស្តែងសាលាខណ្ឌច្បារអំពៅ បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព ពង្រឹងសមត្ថភាពមន្ត្រី កាត់បន្ថយភាពក្រីក្រ និងធានានូវលក្ខខណ្ឌជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យមានភាពល្អប្រសើរឡើង។ សាលាខណ្ឌច្បារអំពៅ បានអនុវត្តន៍នូវផែនការសកម្មភាពរបស់ខ្លួនរហូតដល់លេចចេញនូវសមិទ្ធផលជាច្រើន តាមរយៈការគោរពនូវនីតិរដ្ឋដើម្បីធានានូវភាពស្អាតស្អំនៃការធ្វើសេចក្តីសម្រេចផ្សេងៗ។

បើឆ្លងតាមការមើលពីសមិទ្ធផលនៅក្នុងសាលាខណ្ឌដែលបានធ្វើកន្លងមកនោះ គឺយើងអាចសរុបបានថា ការពង្រឹងអភិបាលកិច្ចល្អក្នុងសាលាខណ្ឌច្បារអំពៅពិតជាមានសារៈសំខាន់ តាមរយៈការខិតខំប្រឹងប្រែងរបស់មន្ត្រី និងការចូលរួមរបស់ប្រជាពលរដ្ឋ។ តាមរយៈការពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អក្នុងខណ្ឌច្បារអំពៅ គឺមានការសហការពីប្រជាពលរដ្ឋចូលរួម និងមានការពេញចិត្តនូវ

គោលនយោបាយ និងគោលការណ៍អភិបាលកិច្ចល្អ មានភាគច្រើនដូចជា វេទិកាសាធារណៈ ប្រជាពលរដ្ឋភាគច្រើនគឺហ៊ានបញ្ចេញនូវមតិផ្ទាល់ខ្លួន និងក្នុងការប្រជុំអនុម័តគម្រោងអភិវឌ្ឍន៍ មូលដ្ឋានក៏មានការចូលរួមជាច្រើនដែរ នេះសបញ្ជាក់ពីការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានស្តីពីកាតព្វកិច្ចរបស់ខ្លួនក្នុងការចូលរួមជាមួយសង្គម និងអត្ថប្រយោជន៍នៃការចូលរួមនេះ។ ប៉ុន្តែទោះជាយ៉ាងណាកង្វះខាត គឺចំណុចខ្សោយពិតជាមានបន្តិចបន្តួចមិនមានភាពល្អឥតខ្ចោះឡើយ។ ហេតុដូចនេះនៅក្នុងការពង្រឹង និងជម្រុញ គឺទាមទារឲ្យមានតួអង្គនៃអភិបាលកិច្ចចូលរួមជាមួយគ្នាដោយមិនអាចខ្វះតួអង្គណាម្នាក់បានឡើយ។

ការបង្កើតផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ខណ្ឌច្បារអំពៅ គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ នៅក្នុងភូមិសាស្ត្រខណ្ឌ ហើយឲ្យកាន់តែមានប្រសិទ្ធិភាព និងបានល្អប្រសើរ ក្នុងការដឹកនាំរៀបចំគម្រោងផែនការដោយមានទិសដៅច្បាស់លាស់។

ជាលទ្ធផល ខណ្ឌច្បារអំពៅ បានធ្វើឲ្យគ្រប់គម្រោងផែនការរបស់ខណ្ឌអាចសម្រេចបានគ្រប់ផ្នែក និងអាចក្តាប់ព័ត៌មានបានគ្រប់ជ្រុងជ្រោយ ពីសភាពការណ៍ និងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋទូទាំងសង្កាត់ដែលស្ថិតក្នុងខណ្ឌរបស់ខ្លួន។

# អនុសាសន៍

រដ្ឋបាលថ្នាក់ខណ្ឌ គឺពិតជាចាំបាច់ណាស់ដែលត្រូវមានលទ្ធភាព និងសម្ភារៈគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន និងអាចសម្រេចជាលទ្ធផលល្អប្រសើរសម្រាប់សង្គមជាតិ។ ដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានដូចដែលបានរៀបរាប់ខាងលើ យើងខ្ញុំសូមបញ្ចេញនូវទមតិផ្ទាល់ខ្លួនខ្លះៗ ក្នុងការជួយពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អក្នុងមូលដ្ឋាន៖

១. គួរតែមានការពង្រឹងនូវធនធានមនុស្ស និងសមត្ថភាពមន្ត្រីជំនាញនៅក្នុងមូលដ្ឋានឃុំ សង្កាត់ ជាពិសេស ខណ្ឌ។

២. គួរតែបន្តជម្រុញឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានបានយល់ដឹងពីសិទ្ធិរបស់ខ្លួន។

៣. ក្រុមប្រឹក្សាខណ្ឌ គួរណាតែ បង្កើតគម្រោងចុះអប់រំផ្សព្វផ្សាយអំពីច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់ភូមិបាល និងច្បាប់នានាព្រមទាំងទោសទណ្ឌ នៅតាមបណ្តាលសង្កាត់នានាឲ្យ ប្រជាពលរដ្ឋបានយល់ដឹង។

៤. ខណ្ឌគួរតែបង្កើនសមត្ថភាពក្នុងការពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងាររបស់សង្កាត់ទាំង ០៨ដែលស្ថិតក្រោមការគ្រប់គ្រងដើម្បីធានាកិច្ចអភិវឌ្ឍឲ្យមានប្រសិទ្ធិភាព និងប្រកបដោយនិរន្តរភាព។

៥. គួរជម្រុញផ្សព្វផ្សាយនូវព័ត៌មានទាំងឡាយ និងឱកាសដល់ប្រជាពលរដ្ឋ ជាពិសេសជនដែលងាយរងគ្រោះ ជនក្រីក្រ និងស្ត្រី។

# ឯកសារយោង

## ផ្នែកទ្រឹស្តី

### សៀវភៅ

- សៀវភៅអភិបាលកិច្ចល្អ របស់ក្រុមការងារគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ ឆ្នាំ២០១០
- សៀវភៅសមត្ថភាព និងរបៀបរបបការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុបណ្ឌិត ហៀង សាង និងអនុបណ្ឌិត ប៉េង ឆុង
- សៀវភៅនីតិរដ្ឋបាលទូទៅ របស់អនុបណ្ឌិត ហៀង សាង សាស្ត្រចារ្យផ្នែកនីតិរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ពលើកទី២ ឆ្នាំ២០១១

## ផ្នែកគតិយុត្ត

### ច្បាប់

- រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ភូមិបាល
- ច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌនិងវប្បធម៌
- ព្រះរាជក្រម នស/រកម/០១៩៦/០៨ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

### ប្រកាស

- សេចក្តីសម្រេចស្តីពីការ បង្កើតគណៈកម្មាធិការ និងជំនួយការនានា
- ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈនៅរដ្ឋបាល
- អនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅរាជធានីភ្នំពេញ

### សេចក្តីសម្រេច

- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការកសាងផែនការ និងថវិកា សម្រាប់ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ
- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការលទ្ធកម្ម
- សេចក្តីសម្រេចស្តីពី ការតែងតាំងគណៈកម្មាធិការដោះស្រាយវិវាទ

## កម្រងឯកសារសកម្មភាព

- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ ឆ្នាំ២០១៧-២០១៩
- សៀវភៅផែនការអភិវឌ្ឍន៍របស់ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ ឆ្នាំ២០១៥-២០១៩

## ឯកសារបទបញ្ជាផ្ទៃក្នុង

បទបញ្ជាផ្ទៃក្នុងសម្រាប់ក្រុមប្រឹក្សាខណ្ឌច្បារអំពៅរាជធានីភ្នំពេញនិងគណៈកម្មាធិការជំនួយ

## កម្រងរបាយការណ៍របស់ខណ្ឌច្បារអំពៅ

- របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ ឆ្នាំ២០១៨
- របាយការណ៍ស្តីពីលទ្ធផលអនុវត្តជន៍ការងាររយៈពេល០៥ឆ្នាំ (ចាប់ពីឆ្នាំ២០១៤-២០១៨)
- របាយការណ៍ស្តីពី សកម្មភាពការងារប្រចាំឆ្នាំ២០១៨ របស់ការិយាល័យកិច្ចការនារី

## គេហទំព័រ

- http://www.undp.org

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ | ផែនទីខណ្ឌច្បារអំពៅរាជធានីភ្នំពេញ |
| ឧបសម្ព័ន្ធទី២ | អនុក្រឹត្យស្តីពី ការបង្កើតខណ្ឌច្បារអំពៅរាជធានីភ្នំពេញ |
| ឧបសម្ព័ន្ធទី៣ | ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| ឧបសម្ព័ន្ធទី៤ | ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ |
| ឧបសម្ព័ន្ធទី៥ | សេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងាររៀបចំទីតាំងរដ្ឋបាលខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ និងមន្រ្តីរាជការដែលត្រូវចាត់ឲ្យទៅបំពេញការងារនៅសាលាខណ្ឌទាំងនោះ |
| ឧបសម្ព័ន្ធទី៦ | សេចក្តីណែនាំស្តីពី ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ក្រុង ស្រុក ខណ្ឌ |
| ឧបសម្ព័ន្ធទី៧ | ដីការស្តីពី បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ |
| ឧបសម្ព័ន្ធទី៨ | ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ឧបសម្ព័ន្ធទី៩ | ភ្ជាប់នឹងដីការក្រុមប្រឹក្សាខណ្ឌលេខ ០១៨/១៧ ដក.ច.អ.ព.អណ២.ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៧ |
| ឧបសម្ព័ន្ធទី១០ | ការអនុវត្តន៍ផែនការសកម្មភាព និងថវិកា ផអ៣ |
| ឧបសម្ព័ន្ធទី១១ | វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគខណ្ឌ |